# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

○ សារាចរលេខ ០១ ស្តីពី ការអនុវត្តន៍គោលនយោបាយនិរន្តរភាព នៃប្រព័ន្ធធារាសាស្ត្រ

○ គោលនយោបាយ សំរាប់កិច្ចដំណើរការ និង ថែទាំប្រព័ន្ធធារាសាស្ត្រដោយនិរន្តរភាព

○ ជំហាននៃការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក


**រៀបរៀងដោយ ក្រសួងធនធានទឹក និង ឧតុនិយម**



ឧបត្ថម្ភដោយ:

- **FAO**
- **PRASAC**
- **ADB**
- **AFD**
- **APS**

ខែ មិថុនា ឆ្នាំ ២០០០

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ក្រសួងធនធានទឹក និង ឧតុនិយម
Ministry of Water Resources
and Meteorology
********

លេខ 306 ប្រក ធទឧ

ម.ព.ឯ.ក AIDOC
Code: 157-030
Date:
Donated by:

# ប្រកាស

## ស្តីពីការប្រើប្រាស់ផ្លូវការនូវឯកសារជាមូលដ្ឋាន
## ដើម្បី បង្កើត និង អភិវឌ្ឍន៍ សហគមន៍កសិករប្រើប្រាស់ទឹក

◇◇◇◇◇◇◇◇◇◇◇◇◇

## រដ្ឋមន្ត្រី ក្រសួងធនធានទឹក និង ឧតុនិយម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រ កម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងធនធានទឹក និង ឧតុនិយម
- បានឃើញអនុក្រឹតលេខ ៥៨ អនក្រ, បក ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ក្រសួងធនធានទឹក និង ឧតុនិយម
- យោងតាមលទ្ធផលនៃអង្គសិក្ខាសាលាជាតិកាលពី ថ្ងៃទី ០៥-០៧ ខែមិថុនា ឆ្នាំ២០០០
- បានឃើញការចាំបាច់ របស់ ក្រសួងធនធានទឹក និង ឧតុនិយម

**<u>សំរេច</u>**

**ប្រការ ១:** ប្រកាសអោយប្រើប្រាស់ជាផ្លូវការនូវឯកសារ ចំនួនបី ដូចខាងក្រោម:

- ឧបសម្ព័ន្ធថ្មីនៃសារាចរលេខ ០១ សរ ចុះថ្ងៃទី ១១ ខែ ០១ ឆ្នាំ១៩៩៩ ស្តីពី ការអនុវត្តន៍គោលនយោបាយនិរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រ
- គោលនយោបាយ សំរាប់កិច្ចដំណើរការ និង ថែទាំប្រព័ន្ធធារាសាស្ត្រដោយនិរន្តរភាព
- ជំហាននៃការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក

**ប្រការ ២:** អគ្គនាយកក្រសួង អគ្គាធិការ និង គ្រប់អង្គភាពចំណុះក្រសួងធនធានទឹក និង ឧតុនិយម ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី ២០ ខែ ៧ ឆ្នាំ ២០០០

**រដ្ឋមន្ត្រី**

លឹម គានហោ

<u>កន្លែងទទួល:</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
-ក្រសួងអភិវឌ្ឍន៍ជនបទ
-ថ្នាក់ដឹកនាំក្រសួងធនធានទឹក និង ឧតុនិយម
-ដូចក្នុងប្រការ ២
-ឯកសារ-កាលប្បវត្តិ

# មាតិកាអត្ថបទ

- ផ្នែកទី ១
- ផ្នែកទី ២
- ផ្នែកទី ៣

# ផ្នែកទី ១

## សារាចរលេខ ០១

## ស្តីពី

## ការអនុវត្តន៍គោលនយោបាយនិរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***៚៙៛***

ដ្ឋាភិបាលកម្ពុជា

: ០១ សរ.

ធនធានទឹក និង ឧតុនិយម
លេខ:...1ៗ៥...............
ថ្ងៃទី...11...ខែ...1...ម៉ោង.......
ម្ដេច..........................

# សារាចរ

## ស្តីពី

## ការអនុវត្តន៍គោលនយោបាយនិរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រ

វិស័យកសិកម្មនៅកម្ពុជា មានតួនាទីយ៉ាងសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍ប្រទេសជាតិព្រោះថាប្រជាជន ប្រមាណ 35% ជាកសិករ ។ ដូចនេះដើម្បីធានាបានលើផ្នែកសន្តិសុខស្បៀងឈានដល់ការនាំ កសិផលចេញ ការងារដោះស្រាយទឹកត្រូវបានចាត់ទុកជាកត្តាគន្លឹះនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលប្រកាន់យក និង ក៏តែងតែមាន តួនាទីពិសេសទៅទៀតសំរាប់ពេលបច្ចុប្បន្ន និង អនាគត ។ ឈរលើទស្សនៈ ខាងលើនេះ ការងារស្តារ និង កសាងប្រព័ន្ធធារាសាស្ត្រ បាននិងកំពុងក្លាយជាចលនាមួយយ៉ាងផុលផុសពីសំណាក់ រាជរដ្ឋាភិបាល អង្គការសង្គម អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុនឯកជន និង សប្បុរសជន ។ល។ ទន្ទឹមនឹងនេះក្នុងគោលបំណង :

- ជំរុញដល់ការជំរុះធានាបាននូវសុវត្ថិភាពស្បៀង និង ការរីកលូតលាស់នៃសេដ្ឋកិច្ចជាតិ ។
- ថែទាំប្រព័ន្ធស្រោចស្រពក្នុងលក្ខណៈប្រើប្រាស់យូរអង្វែង ។
- ពង្រីកបាននូវសមត្ថភាពប្រើប្រាស់ និង សក្តានុពលនៃការស្រោចស្រព ។
- កាត់បន្ថយនូវការចំណាយជាប្រចាំដ៏ធំធេងរបស់រាជរដ្ឋាភិបាល លើកិច្ចដំណើរការ និង ថែទាំប្រព័ន្ធធារាសាស្ត្រ ។
- ទប់ស្កាត់នូវភាពអនាធិបតេយ្យនៃការកសាងប្រព័ន្ធធារាសាស្ត្រ និង ការបំផ្លិចបំផ្លាញ ។
- ទាក់ទាញនូវប្រភពធនធានថវិកាពីអន្តរជាតិ សប្បុរសជនដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍វិស័យ ធារាសាស្ត្រ ។
- ជំរុញអោយកសិករមានភាពម្ចាស់ការលើការប្រើប្រាស់ និង ថែទាំប្រព័ន្ធស្រោចស្រព ដែល ឈានទៅដល់ការផ្ទេរការងារគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រអោយដល់សហគមន៍កសិករប្រើប្រាស់ទឹក ។

ដើម្បីអនុវត្តន៍គោលនយោបាយនិរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រ រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូនក្រសួង ធនធានទឹក និង ឧតុនិយម :

- ត្រូវធ្វើការពិនិត្យពិចារណា និង ធ្វើការវាយតំលៃនូវរាល់ប្រព័ន្ធធារាសាស្ត្រទូទាំងប្រទេសដែលបំរើ អោយការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។
- ត្រូវរៀបចំលក្ខន្តិកៈសហគមន៍កសិករប្រើប្រាស់ទឹកជាតិទូទាំងប្រទេស និង ទទួលបន្ទុកណែនាំការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក ។
- ត្រូវធ្វើការសិក្សាគម្រោងប្លង់ និង សាងសង់ទាំងស្រុងនូវសំណង់ប្រព័ន្ធស្រោចស្រពដើម្បីធ្វើយ៉ាងណាធានាដល់ការផ្តល់ទឹកដល់ដីស្រែ ចំការដំណាំរបស់កសិករ ។
- ត្រូវសហការជាមួយក្រសួងពាក់ព័ន្ធក្នុងការរៀបចំបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវសហការរៀបចំថវិកាដល់កិច្ចដំណើរការសហគមន៍កសិករប្រើប្រាស់ទឹក រហូតដល់ សហគមន៍អាចដំណើរការដោយខ្លួនឯងបានក្នុងនោះត្រូវអនុវត្តទៅតាមរូបមន្តដូចខាងក្រោម :

- ការកំណត់ថ្លៃទឹកសំបចដោយសហគមន៍ប្រើប្រាស់ទឹកក្នុងមួយហិកតា :

$$Y = \frac{X_1 + X_2 + X_3 + X_4 + X_5}{\text{ផ្ទៃដីស្រោចស្រព}} + 20\% \text{ នៃអត្រាកំណើនទិន្នផលក្នុងមួយហិកតា}$$

ក្នុងនេះ X តាងដោយការចំណាយដល់កិច្ចដំណើរការថែទាំ :

$X_1$ = ការចំណាយលើ ការងារជួសជុល និង ថែទាំប្រព័ន្ធស្រោចស្រព

$X_2$ = ការចំណាយលើ ប្រេងឥន្ធនៈ (ក្នុងករណីប្រើប្រាស់ម៉ាស៊ីនបូមទឹក)

$X_3$ = ការចំណាយលើ ការឧបត្ថម្ភដល់គណៈកម្មាធិការសហគមន៍

$X_4$ = ការចំណាយលើ ផ្នែករដ្ឋបាល

$X_5$ = ការចំណាយលើ ការងារផ្សេងៗ

ហើយ Y តាងដោយការកំណត់ថ្លៃទឹកដូចតទៅ :

+ ក្នុងឆ្នាំទី 1 រដ្ឋទទួលបន្ទុក 80% សហគមន៍ត្រូវបង់ 20%
+ ក្នុងឆ្នាំទី 2 រដ្ឋទទួលបន្ទុក 60% សហគមន៍ត្រូវបង់ 40%
+ ក្នុងឆ្នាំទី 3 រដ្ឋទទួលបន្ទុក 40% សហគមន៍ត្រូវបង់ 60%
+ ក្នុងឆ្នាំទី 4 រដ្ឋទទួលបន្ទុក 20% សហគមន៍ត្រូវបង់ 80%
+ ក្នុងឆ្នាំទី 5 រដ្ឋទទួលបន្ទុក 0% សហគមន៍ត្រូវបង់ 100%

តំរោងចំណាយខាងលើនេះ គិតសំរាប់តែប្រភេទសំណង់ប្រព័ន្ធធារាសាស្ត្រណា ដែលស្ថាបនាឡើងដោយ ថវិការដ្ឋ ។

- ការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកត្រូវកំណត់ដោយអក្សរកាត់ "ស.ក.ប.ទ." ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។ ស.ក.ប.ទ. ត្រូវដឹកនាំដោយគណៈកម្មាធិការសហគមន៍ដែលត្រូវជ្រើសតាំងឡើងតាមរយៈនៃការបោះឆ្នោតរបស់សមាជិកសហគមន៍ ។ គណៈកម្មាធិការ ស.ក.ប.ទ. ត្រូវមានភារកិច្ចដូចខាងក្រោម :
  - រៀបចំកម្មវិធីការងាររបស់សហគមន៍
  - អនុវត្តទៅតាមលក្ខន្តិកៈនៃសហគមន៍ដែលបានកំណត់ដោយក្រសួងធនធានទឹក និង ឧតុនិយម
  - រៀបចំកិច្ចដំណើរការ និង ការថែទាំប្រព័ន្ធធារាសាស្ត្រអោយស្ថិតក្នុងក្របខ័ណ្ឌប្រើប្រាស់កំរិតខ្ពស់ និង សន្សំសំចៃ
  - ដោះស្រាយវិបត្តិរបស់សមាជិកសហគមន៍
  - ប្រមូលថ្លៃប្រើប្រាស់ទឹកស្រោចស្រពទៅតាមការកំណត់របស់សហគមន៍
  - កំរិតនៃការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយសហគមន៍កសិករប្រើប្រាស់ទឹក ត្រូវបានកំណត់ភារកិច្ចមួយដោយឡែកទៅតាមភូមិសាស្ត្រ ប្រភេទគំរោងជាក់ស្តែងដែលកំណត់ដោយក្រសួងធនធានទឹក និង ឧតុនិយម ។

- ស.ក.ប.ទ. ត្រូវរៀបចំក្រុមកសិករប្រើប្រាស់ទឹកដែលតំណាងដោយអក្សរកាត់ "ក.ក.ប.ទ."

- ក.ក.ប.ទ. មានភារកិច្ច :
  - អនុវត្តបណ្តាកម្មវិធីការងាររបស់សហគមន៍
  - សំរបសំរួលការងាររវាងសមាជិកក្រុម និង សហគមន៍
  - ប្រមូលថ្លៃប្រើប្រាស់ទឹកពីសមាជិកក្រុមរបស់ខ្លួនតាមការកំណត់របស់សហគមន៍

សមាជិកក្រុមកសិករប្រើប្រាស់ទឹកចាំបាច់ត្រូវដាក់ពាក្យសុំចូលជាសមាជិកក្រុមប្រើប្រាស់ទឹក ដោយផ្អែកលើលក្ខន្តិកៈសហគមន៍ (ភ្ជាប់ឧបសម្ព័ន្ធ) ។

រាជរដ្ឋាភិបាលលើកទឹកចិត្តដល់ក្រុមហ៊ុនឯកជន អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ ឬ បុគ្គលដែលមកបណ្តាក់ទុនវិនិយោគលើការងារធារាសាស្ត្រទំហំតូច និង ទំហំធំ ដោយបង្កើតជាសហគមន៍កសិករប្រើប្រាស់ទឹក ។ រីឯការ កំណត់ថ្លៃប្រើប្រាស់ទឹកអាស្រ័យដោយមានការឯកភាពស្រុះស្រួលគ្នារវាងអ្នកវិនិយោគ និង សហគមន៍កសិករ ប្រើប្រាស់ទឹក ដោយមានការយល់ព្រមពីក្រសួងធនធានទឹក និង ឧតុនិយម ។

រាជរដ្ឋាភិបាលសង្ឃឹមយ៉ាងកក់ក្តៅបំផុតចំពោះគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋានពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិនានានឹងលើកកំពស់ឆន្ទៈអនុវត្តសារាចរនេះអោយបានជោគជ័យ ។

*រាជធានីភ្នំពេញ.ថ្ងៃទី ៣១ ខែមករា ឆ្នាំ១៩៩៩*

នាយករដ្ឋមន្ត្រី

សែន

ចំលងជូន :

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត-ក្រុង
- កាលប្បវត្តិ-ឯកសារ

# ឧបសម្ព័ន្ធ

លក្ខន្តិកៈ

សហគមន៍កសិករប្រើប្រាស់ទឹក

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

៣៩៣✷៤៧

## លក្ខន្តិកៈ សហគមន៍កសិករប្រើប្រាស់ទឹក

### ជំពូក I

### ឈ្មោះ និង គោលបំណងនៃសហគមន៍កសិករប្រើប្រាស់ទឹក

**ប្រការ ១ :** សហគមន៍នេះមានឈ្មោះថា ***សហគមន៍កសិករប្រើប្រាស់ទឹក*** ដែលកំណត់ដោយអក្សរ "ស.ក.ប.ទ"

**ប្រការ ២ :** **សហគមន៍កសិករប្រើប្រាស់ទឹក** នេះមានគោលបំណង :

- ចងក្រងកសិករដែលមានផ្ទៃដីដាំដុះនៅក្នុងតំបន់ស្រោចស្រពដែលមានប្រភពទឹកតែមួយអោយទៅជាក្រុមៗ ដើម្បីងាយស្រួល ក្នុងការផ្គត់ផ្គង់ទឹកសំរាប់ការដាំដុះដល់សមាជិក
- បំរើការងារស្រោចស្រពបានល្អដល់សមាជិកទាំងអស់
- ទទួលចំណេះដឹងលើការងារគ្រប់គ្រង ថែរក្សា និង ដំណើរការប្រព័ន្ធស្រោចស្រព ព្រមទាំង ការងារហិរញ្ញវត្ថុ
- បង្កើនទិន្នផលដំណាំ ក្នុងមួយហិកតាផ្ទៃដី និង បង្កើនរដូវដាំដុះ
- ងាយស្រួលក្នុងការជួយឧបត្ថម្ភពីរដ្ឋ ( អន្តរាគមន៍ក្នុងការជួបឧបសគ្គ និង រកទីផ្សារ)

**ប្រការ ៣ :** "**ស.ក.ប.ទ**"អនុវត្តគោលការណ៍លទ្ធិប្រជាធិបតេយ្យដោយកំណត់យកអង្គប្រជុំសំរាប់សំរេចរាល់ការងារទាំងអស់ដែលទាក់ទងទៅនឹងការស្រោចស្រព ។

**ប្រការ ៤ :** **ស.ក.ប.ទ** ត្រូវមានលក្ខន្តិកៈរបស់ខ្លួន និង ត្រូវបានចុះឈ្មោះក្នុងបញ្ជីរនៅក្រសួង ធនធានទឹក និង ឧតុនិយម ។

### ជំពូក II

### លក្ខណៈសម្បត្តិចូលជាសមាជិក "ស.ក.ប.ទ"

**ប្រការ ៥ :** កសិករដែលមានលក្ខណៈសម្បត្តិដូចខាងក្រោមអាចចូលជាសមាជិកបាន :

- ម្ចាស់ រឺ អ្នកជួលដីពីគេដែលមានផ្ទៃទាំងនោះស្ថិតក្នុងប្រព័ន្ធតែមួយ

- កសិករទាំងពីរភេទដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ

- ក្នុងករណីម្ចាស់ដី រឺ អ្នកជួលដីមានអាយុតិចជាង ១៨ ឆ្នាំ នោះអាណាព្យាបាលរបស់គេត្រូវឈរឈ្មោះជំនួស

- គោរពតាមបទបញ្ជាផ្ទៃក្នុងរបស់ "**ស.ក.ប.ន**"

- ត្រូវដាក់ពាក្យសុំចូលជាសមាជិក "**ស.ក.ប.ន**" ដោយមានស្នាមមេដៃស្តាំ

<u>**ប្រការ ៦**</u> : លក្ខខ័ណ្ឌដែលលែងជាសមាជិក "**ស.ក.ប.ន**"

- ស្លាប់

- ម្ចាស់ដីបានលក់ រឺ ផ្ទេរដីរបស់ខ្លួនអោយអ្នកដទៃ ។

-មិនគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់ "**ស.ក.ប.ន**" ដែលមានចែងក្នុងជំពូក VI ស្តីពី វិធានការ និង បទបញ្ជារបស់ "**ស.ក.ប.ន**"

<u>**ប្រការ ៧**</u> : គ្រប់សមាជិក "**ស.ក.ប.ន**" មានភារកិច្ចដូចខាងក្រោម :

- អនុវត្តការថែទាំ និង ធ្វើអោយប្រព័ន្ធស្រោចស្រពរួមមានភាពប្រសើរឡើង

- អនុវត្តតាមវិធានការ និង បទបញ្ជារបស់សហគមន៍

<u>**ប្រការ ៨**</u> : គ្រប់សមាជិក "**ស.ក.ប.ន**" ត្រូវបានទទួលសិទ្ធិដូចខាងក្រោម :

- បញ្ចេញយោបល់ក្នុងពេលប្រជុំ

- ផ្តល់ឈ្មោះ និង ឈរឈ្មោះអោយគេបោះឆ្នោត

- សុំលាឈប់ពីសមាជិក

- ជួយមតិ និង លើកយោបល់របស់ខ្លួនទៅគណៈកម្មការ "**ស.ក.ប.ន**"

## ជំពូក III

### ខ្សែរយៈចាត់តាំងរបស់ " ស.ក.ប.ន "

<u>**ប្រការ ៩**</u> : "**ស.ក.ប.ន**" ត្រូវដឹកនាំដោយគណៈកម្មាធិការ សហគមន៍ដែលត្រូវជ្រើសតាំងឡើង តាមរយៈនៃការបោះឆ្នោត របស់សមាជិកសហគមន៍ ហើយត្រូវមានសមាសភាពដូចខាងក្រោម :

- ប្រធាន ១រូប ទទួលបន្ទុកក្តាប់រួម
- អនុប្រធានទី១ ១រូប ទទួលបន្ទុកលើកផែនការថែទាំ និងជួសជុល
- អនុប្រធានទី២ ១រូប ទទួលបន្ទុកបែងចែកទឹក
- ហិរញ្ញិក ១រូប ទទួលបន្ទុកគ្រប់គ្រងថវិកា
- ប្រធានក្រុមកសិករប្រើប្រាស់ទឹកទាំងអស់ជាសមាជិក

**<u>ប្រការ ១០</u>** : គណៈកម្មការ "ស.ក.ប.ឧ" មានភារកិច្ចដូចខាងក្រោម :

- រៀបចំកម្មវិធីការងាររបស់សហគមន៍
- កសាងលក្ខន្តិកៈ កិច្ចសន្យា និង បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍
- ថែរក្សាប្រព័ន្ធធារាសាស្ត្រអោយស្ថិតក្នុងលក្ខណៈល្អដើម្បីបំរើដល់កិច្ចដំណើរការស្រោចស្រពបានគ្រប់ពេលវេលា
- គ្រប់គ្រង និង បែងចែកទឹកដល់សមាជិកសហគមន៍
- ពង្រីកនូវសមត្ថភាពនៃការប្រើប្រាស់ ថែទាំ និង អភិវឌ្ឍន៍អោយកាន់តែល្អប្រសើរថែមទៀតនូវប្រព័ន្ធធារាសាស្ត្រ
- ដោះស្រាយវិបត្តិរបស់សមាជិកសហគមន៍
- ប្រមូលថ្លៃប្រើប្រាស់ទឹកស្រោចស្រពទៅតាមការកំណត់របស់សហគមន៍

**<u>ប្រការ ១១</u> : តួនាទី និង ភារកិច្ចរបស់ប្រធានគណៈកម្មាធិការ "ស.ក.ប.ឧ" :**

- ចាត់ចែងអញ្ជើញសមាជិកសហគមន៍ចូលរួមប្រជុំ
- ដឹកនាំអង្គប្រជុំផ្សេងៗដែលពាក់ព័ន្ធ និងការងារស្រោចស្រព
- ដឹកនាំសមាជិករបស់ខ្លួនដើម្បីរៀបចំផែនការស្រោចស្រពនៃឆ្នាំនិមួយៗ នូវគំរោងផែនការចំណាយ និង ការចំណាយមុនពេលអនុវត្តការងារ
- អនុវត្តការងារទៅតាមគំរោងផែនការ និងកម្មវិធីដែលយល់ព្រមពីកិច្ចប្រជុំទូទៅ
- ត្រួតពិនិត្យរាល់សកម្មភាពតាមផ្នែកនិមួយៗរបស់ក្រុម
- សបកោរ និងទំនាក់ទំនងសាធារណៈ
- អនុវត្តការចំណាយទៅតាមការសំរេចនៃការប្រជុំរបស់គណៈកម្មាធិការ "ស.ក.ប.ឧ"
- ដាក់បញ្ចូលគំរោងថវិកាប្រចាំឆ្នាំ និងកម្មវិធីការងាររបស់សហគមន៍ទៅក្នុងកិច្ចប្រជុំទូទៅ

- ករណីអវត្តមានប្រធាន ត្រូវប្រគល់សិទ្ធិទៅអោយអនុប្រធានដឹកនាំការងារ
- ក្នុងករណីអនុប្រធានអវត្តមានប្រធានត្រូវប្រគល់ទៅអោយសមាជិកណាម្នាក់ដឹកនាំការងារ
- ត្រូវតែមានការចុះហត្ថលេខារួមគ្នាក្នុងការផ្ទេរ ឬក៏ លើការចាយវាយផ្សេងៗ
- ធ្វើជាអាជ្ញាកណ្តាលរាល់ជម្លោះរបស់សមាជិកសហគមន៍
- ពិន័យដល់សមាជិកណាដែលមិនអនុវត្តទៅតាមតួនាទី និងភារកិច្ចរបស់សហគមន៍

**ប្រការ ១២ : តួនាទី និងភារកិច្ចរបស់អនុប្រធានទី ១ :**

- ត្រួតពិនិត្យជាប្រក្រតី នូវប្រព័ន្ធស្រោចស្រព
- កំណត់ទំហំការងារដល់កសិករដើម្បីអនុវត្តការងារជួសជុល និងថែទាំ
- ទប់ស្កាត់ការកាប់បំផ្លាញទំនប់បង្ហូរទឹកសំរាប់ចាប់ត្រី និង ដឹកគោ ក្របី លើខ្នងទំនប់
- លើកគំរោងជួសជុលប្រព័ន្ធស្រោចស្រព ដើម្បីដាក់ជូនគណៈកម្មការសហគមន៍ ដើម្បីពិនិត្យ និង សំរេច
- រាយការណ៍ជាប្រចាំនូវការងារជួសជុលប្រព័ន្ធស្រោចស្រព
- ជាជំនួយការអោយគណៈកម្មការសហគមន៍

**ប្រការ ១៣ : តួនាទី និង ភារកិច្ចរបស់អនុប្រធានទី ២**

- រៀបចំកម្មវិធីស្រោចស្រពសំរាប់ការដាំដុះ ដោយមានការឯកភាពគ្នាពីគ្រប់សមាជិក
- ប្រគល់ភារកិច្ចទទួលខុសត្រូវអនុវត្តកម្មវិធីស្រោចស្រពដល់ប្រធានក្រុមប្រើប្រាស់ទឹក
- ត្រួតពិនិត្យការអនុវត្តន៍កម្មវិធីស្រោចស្រព
- រាយការណ៍ជាប្រចាំជូនប្រធានសហគមន៍នូវសកម្មភាពការងារស្រោចស្រព

**ប្រការ ១៤ : តួនាទី និង ភារកិច្ចរបស់ហិរញ្ញិក និង បេឡា :**

- ប្រមូលថ្លៃប្រើប្រាស់ទឹកពីសមាជិកសហគមន៍តាមរយះប្រធានក្រុមប្រើប្រាស់ទឹក
- ធ្វើបញ្ជី និង គ្រប់គ្រងអចលនវត្ថុរបស់សហគមន៍
- គ្រប់គ្រងរាល់បណ្តាចំណូលចំណាយរបស់សហគមន៍
- របាយការណ៍ពីស្ថានភាពចំណូលចំណាយរបស់សហគមន៍ចំពោះមុខគណៈ

កម្មាធិការ "**ស.ក.ប.ឆ**"

**ប្រការ ១៥ :** ខ្សែរយះចាត់តាំងថ្នាក់ក្រោមរបស់ "**ស.ក.ប.ឆ**" គឺក្រុមកសិករប្រើប្រាស់ទឹក ដែលតំណាងដោយ អក្សរកាត់ "**ក.ក.ប.ឆ**"

**ប្រការ ១៦ : តួនាទី និង ភារៈកិច្ចរបស់ប្រធាន "ក.ក.ប.ទ"**

- អនុវត្តបណ្តាកម្មវិធីការងាររបស់សហគមន៍
- សំរបសំរួលការងាររវាងសមាជិកក្រុមទៅសហគមន៍
- ប្រមូលថ្លៃប្រើប្រាស់ទឹកពីសមាជិកក្រុមរបស់ខ្លួនតាមការកំណត់របស់សហគមន៍

**ប្រការ ១៧ : ក្រុមកសិករប្រើប្រាស់ទឹក "ក.ក.ប.ទ"**

ក្រុមកសិករប្រើប្រាស់ទឹក គឺជាកសិករដែលប្រើប្រាស់ទឹកក្នុងតំបន់ស្រោចស្រពជាមួយគ្នា ។ ការបែងចែកក្រុមកសិករប្រើប្រាស់ទឹករបស់សហគមន៍កសិករប្រើប្រាស់ទឹកមួយត្រូវផ្អែកទាំងស្រុងទៅលើភូមិសាស្ត្រដីស្រែ និង លក្ខខ័ណ្ឌនៃប្រព័ន្ធស្រោចស្រពក្នុងតំបន់នោះ។ ក្រុមកសិករប្រើប្រាស់ទឹក ដឹកនាំដោយប្រធានមួយរូបដែលកើតឡើងដោយការបោះឆ្នោត ពីសមាជិកទាំងអស់នៃក្រុមប្រើប្រាស់ទឹក និង អាចមានជំនួយការអោយប្រធានទៅតាមសេចក្តីត្រូវការរបស់ក្រុម ។

## ជំពូក IV

### អាណត្តិ និង ការប្រព្រឹត្តិទៅរបស់ ស.ក.ប.ទ

**ប្រការ ១៨** : អាណត្តិរបស់គណៈកម្មាធិការ "ស.ក.ប.ទ " មានរយៈពេល ៣ ឆ្នាំ

**ប្រការ ១៩ : ការប្រព្រឹត្តិទៅរបស់ គណៈកម្មាធិការ " ស.ក.ប.ទ "**

សមាសភាពរបស់គណៈកម្មាធិការ "ស.ក.ប.ទ "ចាស់អាចមានសិទ្ធិឈរឈ្មោះ

សំរាប់អាណត្តិបន្តបាន ។

ប្រធានក្រុមប្រើប្រាស់ទឹកអាចឈរឈ្មោះសំរាប់តំណែងប្រធាន ឬអនុប្រធានសហគមន៍ ។

នៅពេលដែលប្រធានក្រុមប្រើប្រាស់ទឹកណាមួយត្រូវបានជ្រើសតាំងថ្នាក់ប្រធាន រឺ អនុប្រធាន គណៈកម្មាធិការ "ស.ក.ប.ទ "ក្រុមនោះត្រូវជ្រើសរើសប្រធានមួយរូបទៀតជំនួស ។

**ប្រការ ២០ : វិធីសាស្ត្រជ្រើសរើសគណៈកម្មការសហគមន៍**

ការជ្រើសរើសគណៈកម្មាធិការសហគមន៍ ត្រូវធ្វើឡើងតាមរយៈនៃការបោះឆ្នោតដាច់ដោយឡែកពីគ្នា :

បោះឆ្នោតលើកទី ១ សំរាប់ថ្នាក់ប្រធាន បោះឆ្នោតលើកទី ២ សំរាប់អនុប្រធានទី ១ បោះឆ្នោតលើកទី៣ សំរាប់អនុប្រធានទី ២ បោះឆ្នោតលើក ៤ សំរាប់ ហិរញ្ញិក ។ ការអនុម័តសំរេចយកជាបានការលុះត្រាតែមានការឯកភាពដែលមានសំលេងភាគច្រើននៃសមាជិកដែលបានចូលរួមក្នុងការបោះឆ្នោត ។ ការបោះឆ្នោតអាចប្រព្រឹត្តិទៅបានលុះត្រាតែមានវត្តមានរបស់សមាជិកសហគមន៍កសិករប្រើប្រាស់ទឹកយ៉ាងតិច២/៣នៃសមាជិកសរុប ។ ក្នុងករណីអវត្តមានសមាជិកដែលចូលរួមក្នុងការបោះឆ្នោតមិនគ្រប់ចំនួន២/៣នៃសមាជិកសរុបដែលធ្វើអោយការបោះឆ្នោតមិនអាចប្រព្រឹត្តិទៅបាននោះ ការបោះឆ្នោតលើកទី ២ ត្រូវបានកំណត់រយៈពេល ៣ ថ្ងៃក្រោយ ។ លទ្ធផលនៃការបោះឆ្នោតត្រូវបានប្រកាស និង ទទួលស្គាល់ ពីតំណាងក្រសួងធនធានទឹក និង ឧតុនិយម ។

**ប្រការ ២១ ៖ កិច្ចប្រជុំ**

រាល់ការប្រជុំត្រូវមានសមាជិកចូលរួមពី ២/៣ នៃសមាជិកសរុបដែលចូលរួម ។ ក្នុងករណីដែលវត្តមានរបស់សមាជិកដែលត្រូវចូលរួមប្រជុំមិនគ្រប់ចំនួន ២ /៣ទេនោះ ការប្រជុំលើកទី ២ នឹង ត្រូវកំណត់ធ្វើរយៈពេល ៣ ថ្ងៃក្រោយជាកំហិត ។ អង្គប្រជុំនិមួយៗត្រូវដឹកនាំដោយប្រធាន ក្នុងករណីប្រធានអវត្តមានត្រូវប្រគល់ភារៈកិច្ចអោយអនុប្រធានដឹកនាំ ។ ប្រសិនបើអនុប្រធានអវត្តមានទៀតនោះប្រធានត្រូវប្រគល់ភារៈកិច្ចដឹកនាំការប្រជុំនេះអោយ ទៅសមាជិកណាមួយដឹកនាំការងារនេះ។ ការប្រជុំសាមញ្ញអាចធ្វើជារៀងរាល់ខែដោយអនុលោមទៅតាមគោលបំណងរបស់សហគមន៍ដើម្បីត្រួតពិនិត្យឡើងវិញ នូវការអនុវត្តន៍គំរោងផែនការដែលបានអនុម័តក្នុងពេលប្រជុំរួមនិងដាក់ចេញនូវវិធានការសំរាប់អនុវត្តបន្ត ។ ក្នុងករណីមានការងារចាំបាច់ ពិសេសដែលត្រូវដោះស្រាយបន្ទាន់ការប្រជុំវិសាមញ្ញអាចនិងត្រូវប្រព្រឹត្តិឡើងគ្រប់ពេលវេលាតាមការស្នើរនៃចំនួនសមាជិក ២ /៣ ។ គ្រប់ការប្រជុំត្រូវចាត់តាំងលេខាកត់ត្រាម្នាក់សំរាប់ធ្វើកំណត់ហេតុនៃការប្រជុំ។ លេខាកត់ត្រាត្រូវធ្វើកំណត់ហេតុប្រជុំដោយចែកជូនទៅសមាជិកគ្រប់រូបអោយបានមុនការប្រជុំលើកទី២ យ៉ាងតិច ១០ថ្ងៃ ។ ការប្រជុំមានបែងចែកជា ៣ ប្រភេទ និង តាមលំដាប់លំដោយដូចខាងក្រោម :

- ប្រជុំគណៈកម្មាធិការ "**ស.ក.ប.ឧ**"

-ប្រជុំរវាងប្រធានក្រុមកសិករប្រើប្រាស់ទឹកជាមួយសមាជិករបស់ខ្លួនត្រូវកំណត់ ធ្វើឡើងយ៉ាងតិច៧ថ្ងៃមុនការប្រជុំរបស់គណៈកម្មាធិការ "ស.ក.ប.ឌ " ជាមួយប្រធានក្រុមកសិករប្រើប្រាស់ទឹក ។ គោលបំណងនៃការប្រជុំនេះគឺដើម្បីវាយតំលៃលើសកម្មភាពការងារក្នុងក្រុមរបស់ខ្លួន ។

- ប្រជុំរួម : ការប្រជុំត្រូវអនុវត្តមុន និងក្រោយការដាំដុះ ក្នុងទិសដៅ :

◆ មុនដាំដុះ : - រៀបចំផែនការជួសជុល

- រៀបចំផែនការដាំដុះអោយសមាមាត្រទៅនឹង ផែនការស្រោចស្រព

- ធ្វើផែនការអំពីចំណូល និង កំណត់ការចំណាយ

◆ ក្រោយដាំដុះ : - វាយតំលៃទិន្នផលដាំដុះ

- តុល្យភាពចំណូល និង ចំណាយជាក់ស្តែងក្នុងរដូវកន្លងមក

## ជំពូក V

### ចំណូល ចំណាយ និង ការត្រួតពិនិត្យ របស់ "ស.ក.ប.ឌ"

**ប្រការ ២២ : ប្រភពចំណូល**

ប្រភពចំណូលរបស់សហគមន៍កសិករប្រើប្រាស់ទឹក បានមកពី :

- ថ្លៃប្រើប្រាស់ទឹករបស់សមាជិកសហគមន៍
- ជំនួយឥណទានពី រដ្ឋ អង្គការ I.O & N.G.O
- ផលចំណេញដែលបានមកពីការធ្វើអាជីវកម្មរបស់សហគមន៍
- ប្រាក់ពិន័យ និង ការយកពន្ធផ្សេងៗ

**ប្រការ ២៣ : មុខសញ្ញាដែលត្រូវចំណាយ**

- ការចំណាយលើ ការងារជួសជុល និងថែទាំប្រព័ន្ធស្រោចស្រព តាងដោយ $X_1$
- ការចំណាយលើ ប្រេងឥន្ធនៈ តាងដោយ $X_2$
- ការចំណាយលើ ការឧបត្ថម្ភដល់គណៈកម្មាធិការសហគមន៍ តាងដោយ $X_3$
- ការចំណាយលើ ផ្នែករដ្ឋបាល តាងដោយ $X_4$
- ការចំណាយលើ ការងារផ្សេងៗ តាងដោយ $X_5$

**ប្រការ ២៤ ៖ គោលការណ៍បង់ថ្លៃទឹកត្រូវកំណត់តាមរូបមន្តដូចខាងក្រោម ៖**

-ថ្លៃប្រើប្រាស់ទឹក ក្នុងមួយហិកតា ត្រូវកំណត់តាមរូបមន្តដូចខាងក្រោម ៖

$$Y = \frac{X_1 + X_2 + X_3 + X_4 + X_5}{\text{ផ្ទៃដីស្រោចស្រព}} + 20\%$$ នៃអត្រាកំណើនទិន្នផលក្នុងមួយហិកតា

- ក្នុងថ្លៃ Y នេះគឺ ៖

+ ក្នុងឆ្នាំទី 1 រដ្ឋទទួលបន្ទុក 80% សហគមន៍ត្រូវបង់ 20%

+ ក្នុងឆ្នាំទី 2 រដ្ឋទទួលបន្ទុក 60% សហគមន៍ត្រូវបង់ 40%

+ ក្នុងឆ្នាំទី 3 រដ្ឋទទួលបន្ទុក 40% សហគមន៍ត្រូវបង់ 60%

+ ក្នុងឆ្នាំទី 4 រដ្ឋទទួលបន្ទុក ២0% សហគមន៍ត្រូវបង់ 80%

+ ក្នុងឆ្នាំទី 5 រដ្ឋទទួលបន្ទុក 0% សហគមន៍ត្រូវបង់ 100%

សំរាប់ការអនុវត្តន៍ជាក់ស្តែងគឺគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកត្រូវប្រមូលតែ ១៤០ គក ក្នុង ១ ហត សំរាប់ ២០ ភាគរយនៃកំណើន ។ ត្រូវអនុវត្តន៍យ៉ាងហោចណាស់រយៈពេល៥ឆ្នាំដំបូងហើយបន្ទាប់មកអាចធ្វើការផ្លាស់ប្តូរទៅតាមស្ថានភាពថវិការរបស់សហគមន៍ ។ អាចធ្វើការចុះថ្លៃលើតំលៃនៃ២០ភាគរយតែមិនអោយចុះរហូតតិចជាង៥ភាគរយទេ ។

**ប្រការទី២៥:** ក-បញ្ជីការគណនេយ្យនៃ **ស.ក.ប.ឌ** ត្រូវតែមានការត្រួតពិនិត្យជារៀងរាល់ឆ្នាំ ដោយ ក្រុមអធិការកិច្ចដែលបង្កើតឡើងដោយ ក្រសួងធនធានទឹក និង ឧតុនិយម និង គណៈកម្មាធិការ **ស.ក.ប.ឌ** ។

ខ-ឯកសារនៃប្រាក់ចំណូលនិងចំណាយរបស់ **ស.ក.ប.ឌ** និងរបាយការណ៍របស់ក្រុមអធិការកិច្ច ត្រូវដាក់ជូនទៅអង្គប្រជុំពេញអង្គរបស់ **ស.ក.ប.ឌ** អោយបានទៀងទាត់ក្នុងរយៈពេល----- ខែម្តង ជារៀងរាល់ឆ្នាំ ដើម្បីធ្វើការអនុម័ត ។ **ស.ក.ប.ឌ** ត្រូវផ្ញើឯកសារទាំងនេះជូន ក្រសួងធនធានទឹក និង ឧតុនិយម មួយច្បាប់ (នាយកដ្ឋានធារាសាស្ត្រកសិកម្ម) ។

គ-គ្រប់ក្រុមកសិករប្រើប្រាស់ទឹកទាំងអស់ត្រូវដាក់ជូនគណៈកម្មាធិការ **ស.ក.ប.ឌ** នូវឯកសារ ចំណូល និង ចំណាយ ១៥ ថ្ងៃមុនពេលធ្វើអធិការកិច្ច ។

## ជំពូក VI

## វិធានការ និង បទបញ្ជា

**ប្រការ ២៦** : សមាជិក "ស.ក.ប.ឧ" ត្រូវចូលរួមប្រជុំតាមការកំណត់និងតាមការអញ្ជើញ របស់គណៈកម្មាធិការ "ស.ក.ប.ឧ"

**ប្រការ ២៧** :គ្រប់សមាជិក "ស.ក.ប.ឧ" ដែលមានស្រែនៅដើមប្រឡាយត្រូវអនុញ្ញាតិអោយសមាជិកដទៃទៀតដែលមានស្រែនៅបន្ទាប់ រឺ ឆ្ងាយក្នុងការធ្វើប្រឡាយដើម្បីនាំទឹក បញ្ចូលស្រែ ។

**ប្រការ ២៨** :ក្នុងការបង្ហូរទឹកបញ្ចូលស្រែ សមាជិក "ស.ក.ប.ឧ"ត្រូវរង់ចាំទទួលទឹករហូតដល់ទឹកល្មម គ្រប់គ្រាន់ក្នុងស្រែរបស់ខ្លួន ។

**ប្រការ ២៩** : សមាជិក "ស.ក.ប.ឧ" ត្រូវចូលរួមថែទាំបណ្តាសំណង់ទ្វារទឹក និង ទំនប់តាមប្រឡាយក្បាលដីដែលមានស្រាប់ ដូចជាការលើកទប់ភ្លឺប្រឡាយដែលខូចខាត ដាំដើមឈើការពារទំនប់ ការពារមិនអោយដឹកសត្វពាហនៈលើខ្នងទំនប់ និង ភ្លឺប្រឡាយ រឺ ជីករន្ធក្តាមជាដើម ។

**ប្រការ ៣០** : សមាជិក "ស.ក.ប.ឧ" ត្រូវចូលរួមជួសជុល និងថែទាំទ្រង់ទ្រាយធំ តាមរយៈនៃការចូលរួមពលកម្ម រឺចេញជាប្រាក់ជារៀងរាល់រដូវតាមការកំណត់ របស់អង្គប្រជុំ ។

**ប្រការ ៣១** : ក្នុងករណីមានការផ្ទេរ រឺ លក់ដីក្នុងតំបន់ស្រោចស្រព ម្ចាស់ដីត្រូវរាយការណ៍ ជូនគណៈកម្មាធិការ "ស.ក.ប.ឧ" ជាបន្ទាន់ ។

**ប្រការ ៣២** : គណៈកម្មាធិការ "ស.ក.ប.ឧ"ត្រូវធានាការបែងចែកទឹកសំរាប់ ស្រោចស្រពដំណាំរបស់សមាជិកតាមគំរូវការប្រកបដោយភាពយុត្តិធម៌ ។

**ប្រការ ៣៣** : គណៈកម្មការ "ស.ក.ប.ឧ"ត្រូវតែទូទាត់បញ្ជី និង ពន្យល់អំពីចំណូល និងចំណាយ នៅពេលប្រជុំរួមម្តង១ ។

**ប្រការ ៣៤** :ថវិកាដែលប្រមូលបានពីការបង់ថ្លៃទឹក និង ចំណូលផ្សេង១ គណៈកម្មាធិការ "ស.ក.ប.ឧ" ត្រូវយកទៅផ្ញើធនាគារ ដោយឆ្លងតាមការសំរេចរបស់អង្គប្រជុំ ។

**ប្រការ ៣៥** :ការដកថវិកាដែលបានដាក់នៅធនាគារ ត្រូវចុះហត្ថលេខាដោយប្រធានគណៈ

កម្មាធិការ " ស.ក.ម.ន " ក្រោយពីបានទទួលការសំរេចរបស់ គណៈកម្មាធិការក្នុងការយកថវិកានេះទៅធ្វើអ្វីមួយ ។

**ប្រការ ៣៦** : ប្រធានអាចទុកប្រាក់ខ្លះនៅក្នុងបេឡាសំរាប់ចំណាយផ្សេងៗដែលចាំបាច់និងបន្ទាន់ តែមិន អោយលើសពីចំនួន................រៀលទេ ។

## ជំពូក VII

## ការដាក់ពិន័យ

**ប្រការ ៣៧ : ការពិន័យ**

ពិន័យនូវរាល់សកម្មភាពណាដែលបានបង្កឡើងនូវភាពអសកម្ម ដែលចាត់ទុកថាជាអំពើខុស ឆ្គង និង ត្រូវមានទោស និង ជាកម្មវត្ថុនៃការពិន័យដែលទាក់ទង នឹងចំនួនថវិកាត្រូវបានកំណត់ដូចខាងក្រោមនេះ :

- មិនបានចូលរួមប្រជុំជាប់ៗគ្នាចំនួន ៣ ដងត្រូវពិន័យជាប្រាក់ចំនួន..............រៀល រឺ បញ្ឈប់ជាសមាជិកសហគមន៍ ។
- មិនបានចូលរួមធ្វើពលកម្ម នៅក្នុងការថែទាំលើកឡើងដោយសមាជិកក្រុម គឺត្រូវ :
  . ព្រមាន
  . ពិន័យជាប្រាក់ចំនួន...........................រៀល
  . មិនផ្តល់ទឹកអោយចំនួន.......................ថ្ងៃ រឺ
  . យកទៅប្រគល់អោយអាជ្ញាធរឃុំ-សង្កាត់ ដើម្បីមានវិធានការ
- ការលួចទឹកពីប្រឡាយដើម្បីយកទៅស្រោចស្រពត្រូវពិន័យជាប្រាក់ចំនួន..........រៀល ។
- ករណីអ្នកត្រួតពិនិត្យទ្វារទឹកនៅក្បាលប្រឡាយមិនបានដំណើរការទៅតាមការកំណត់ រឺ ដោយមានអ្នកលួចបិទទ្វារទឹកត្រូវពិន័យជាប្រាក់ចំនួន................រៀល ។ ប្រសិនមានការបិទទ្វារទឹកដើម្បីមានគោលបំណងចាប់ត្រី និងមានប្រដាប់ប្រដាចាប់ត្រីត្រូវដកយកសំភារៈទាំងនោះបន្ថែមលើថវិកាពិន័យទៀត ។

-ការកាប់ភ្លឺ រឺធ្វើអោយខូចខាតប្រព័ន្ធប្រឡាយរឺសំណង់សិល្បការត្រូវពិន័យជាប្រាក់ចំនួន......រៀល ហើយអ្នកនោះត្រូវជួសជុលអោយបានត្រឹមត្រូវឡើងវិញ ។ ប្រសិនបើអ្នកធ្វើអោយ

ខូចខាតជាកុមារនោះអាណាព្យាបាល ត្រូវតែធ្វើការជួសជុល រឺ សងជាទឹកប្រាក់តាមទំហំនៃការខូចខាត ។

- ការដឹកសត្វពាហនៈចុះឡើងក្នុងប្រឡាយ ត្រូវពិន័យជាប្រាក់ចំនួន....................រៀល រឺ យកសត្វទៅឃុំឃាំងរហូតដល់ការពិន័យត្រូវបានបង់ ។

- ការចាប់ត្រីក្នុងប្រឡាយអាចអនុញ្ញាតិចំពោះ សំណាញ់ មង សន្ទូច អង្រុត អួសមង ។ តែការងារនេះអាស្រ័យលើសមាជិកសហគមន៍សំរេច និង មិនអនុញ្ញាតិចំពោះការដាក់ទ្រូ លប ការបិទបាចត្រី ការជីករន្ធ បើប្រព្រឹត្តិល្មើសត្រូវពិន័យជាប្រាក់ ចំនួន.............រៀល ។

- ភាពខ្វះខ្វាយទឹកសំរាប់យកទៅស្រោចស្រព ត្រូវពិន័យជាប្រាក់ចំនួន............រៀល ។

-ការប្រើប្រាស់អារុធរឺគ្រឿងផ្ទុះធ្វើអោយខូចខាតដល់ប្រព័ន្ធ ត្រូវពិន័យជាប្រាក់ចំនួន....... រៀល ។

-ការបិទទំនប់កាត់ប្រឡាយដើម្បីយកទឹកទៅស្រោចស្រពរឺដើម្បីធ្វើអ្វីផ្សេងៗនៅក្នុងប្រឡាយត្រូវពិន័យជាប្រាក់ចំនួន............រៀល ។

-ការមិនព្រមបង់ប្រាក់ពិន័យ រឺ ក៏ប្រើអំណាចឃោរឃៅរបស់បុគ្គលិកក្នុងសមាជិកនឹងត្រូវដោះស្រាយបញ្ជូនទៅអាជ្ញាធរឃុំ រឺ សង្កាត់ដើម្បីដោះស្រាយ ។ ចំពោះសកម្មភាពរបស់សហគមន៍ដែលចាត់ថាជាអំពើខុសឆ្គង និង ជាកម្មវត្ថុនៃការ ពិន័យគឺទៅតាមលក្ខណៈដែលពាក់ព័ន្ធ នឹងត្រូវបានកំណត់ចំនួនដូចខាងក្រោម :

១ ពុំបានថែទាំប្រឡាយ និង បន្តការខ្វះខ្វាយទឹករបស់សហគមន៍

. ទុកក្នុងការព្រមាន

. ត្រូវពិន័យចំនួន..............រៀល

. ត្រូវផ្អាកទឹករយៈពេល...........ថ្ងៃ

១ មិនគោរពតាមកម្មវិធីបែងចែកទឹកដែលកំណត់ដោយសហគមន៍ :

. ទុកក្នុងការព្រមាន

. ត្រូវពិន័យចំនួន..............រៀល

. ត្រូវផ្អាកទឹករយៈពេល...........ថ្ងៃ

# អង្គការលេខ សហគមន៍កសិករប្រើប្រាស់ទឹក




## គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក

| | | |
|---|---|---|
| ១- ប្រធាន | ១ រូប | ទទួលបន្ទុកគ្រប់រួម |
| ២- អនុប្រធានទី១ | ១ រូប | ទទួលបន្ទុកលើផែនការថែទាំ និងជួសជុល |
| ៣- អនុប្រធានទី២ | ១ រូប | ទទួលបន្ទុកបែងចែកទឹក |
| ៤- ហិរញ្ញិក | ១ រូប | ទទួលបន្ទុកគ្រប់គ្រងថវិកា |

៥- ប្រធានក្រុមកសិករប្រើប្រាស់ទឹកទាំងអស់ជាសមាជិក

## ក្រុមកសិករប្រើប្រាស់ទឹក

| | |
|---|---|
| ១- ប្រធាន | ១ រូប |

២- ជំនួយការតាមសេចក្តីត្រូវការរបស់ក្រុម

# ផ្នែកទី ២

## គោលនយោបាយ
## សំរាប់
## កិច្ចដំណើរការ និង ថែទាំប្រព័ន្ធធារាសាស្ត្រ
## ដោយនិរន្តរភាព

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គោលនយោបាយសំរាប់ កិច្ចដំណើរការ និង ថែទាំប្រព័ន្ធធារាសាស្ត្រ ដោយនិរន្តរភាព

រៀបរៀង ដោយក្រសួងធនធានទឹក និង ឧតុនិយម

ខែ មិថុនា ឆ្នាំ ២០០០

# ជំពូក១

## ១_១ សេចក្ដីផ្ដើម

វិស័យកសិកម្មនៅកម្ពុជា គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ ដែលមានប្រជាជនប្រមាណ ៨៥% ជាអ្នករស់នៅជនបទ។ អាស្រ័យហេតុនេះ នយោបាយទឹកនិយាយជារួម ដោយឡែក ការងារធារាសាស្ត្រជាកត្តាចាំបាច់សំរាប់ការអភិវឌ្ឍន៏វិស័យកសិកម្មដើម្បីឆ្ពោះទៅកាន់សន្តិសុខ ស្បៀង និង ការនាំចេញ។ លទ្ធភាពនៃការងារស្រោចស្រពបច្ចុប្បន្នទើបមានត្រឹមតែ ២២%នៃផ្ទៃដីស្រូវសរុប។ ពាមពត៌មានដែលមានស្រាប់ បង្ហាញអោយឃើញថាប្រទេសកម្ពុជាបានប្រើប្រាស់ត្រឹមតែ១% នៃធនធានទឹកដែលខ្លួនមាន ក្នុងនោះ ៨២% បានប្រើសំរាប់ការងារកសិកម្ម។ ការដាំដុះពីរដងក្នុងមួយឆ្នាំដោយប្រើប្រាស់ការស្រោចស្រពទាំងស្រុង ឬ បន្ថែម គឺមានកំរិតតិចតួចនៅឡើយ។ ផលិតផលស្រូវក៏នៅមានកំរិតទាប ជាមធ្យម ២ត ក្នុង ១ ហត។ ការស្តារ និង សាងសង់ប្រព័ន្ធធារាសាស្ត្រ គឺជាកិច្ចការចំបងរបស់រាជរដ្ឋាភិបាលកម្ពុជា។ នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ សកម្មភាពចូលរួមពីកសិករប្រើប្រាស់ទឹកទាំងឡាយ គឺសំខាន់ណាស់ ក្នុងគ្រប់ដំណាក់កាល និង គ្រប់កំរិត។ ដើម្បីទទួល បានជោគជ័យលើការងារអភិវឌ្ឍន៏វិស័យធារាសាស្ត្រ ដោយធានាបាននិរន្តរភាពលើកិច្ចដំណើរការ និង ថែទាំ រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចជូនក្រសួងធនធានទឹក និង ឧតុនិយម ធ្វើការងារត្រួតពិនិត្យ និង វាយតំលៃលើរាល់ប្រព័ន្ធធារាសាស្ត្រដែលមានសក្តានុពលប្រើប្រាស់ប្រកបដោយប្រសិទ្ធិភាពដើម្បីអភិវឌ្ឍន៏សេដ្ឋកិច្ចជាតិ។ ធ្វើគំរូលក្ខន្តិកៈសំរាប់សហគមន៏កសិករប្រើប្រាស់ទឹក ដើម្បីសំរួលក្នុងការរៀបចំកសិករអោយទៅជាសហគមន៏កសិករប្រើប្រាស់ទឹក សិក្សាគ្រោងប្លង់ ធ្វើការជួសជុល និង សាងសង់ប្រព័ន្ធធារាសាស្ត្រដែលរួមមានសំណង់សិល្បការ និង ប្រព័ន្ធប្រឡាយ ដើម្បីផ្តល់ទឹកស្រោចស្រពជូនកសិករអោយបានគ្រប់គ្រាន់ និង មាននិរន្តរភាព ដោយ សហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីបង្កើតសហគមន៏កសិករប្រើប្រាស់ទឹក។

## ១_២ គោលការណ៏សំខាន់ៗ

ក្នុងឆ្នាំ១៩៩៩រាជរដ្ឋាភិបាលបានចេញនូវសារាចរលេខ០១ស្តីពីការអនុវត្តគោលនយោបាយនិរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រ។ គោលនយោបាយនេះ ត្រូវទទួលបានការគាំទ្រពីសហគមន៏អន្តរជាតិ និង ចាត់ទុកជាកត្តាសំខាន់ដើម្បីកំណត់នូវការអនុវត្តន៏កម្មវិធីអភិវឌ្ឍន៏វិស័យធារាសាស្ត្រ និង គ្រប់គ្រងកម្មវិធីប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និង និរន្តរភាពក្នុងក្របខ័ណ្ឌទូទាំងប្រទេស។

គោលនយោបាយនេះផ្អែកលើគោលការណ៏ជាមូលដ្ឋានដូចតទៅៈ

- លក្ខន្តិកៈស្របច្បាប់សំរាប់សហគមន៏កសិករប្រើប្រាស់ទឹក។
- ការពាក់ព័ន្ធនៃសហគមន៏កសិករប្រើប្រាស់ទឹកក្នុងប្រព័ន្ធការងារអភិវឌ្ឍន៏។
- ភារកិច្ចរបស់កសិករក្នុងការបង់ថវិកាសំរាប់ កិច្ចដំណើរការ និង ការថែទាំ និង ជួសជុលបន្ទាន់ផ្សេងៗ។
- ថែទាំ និង កែលំអជាប្រចាំនូវប្រព័ន្ធស្រោចស្រពដែលមានស្រាប់។

-ចាត់ចែងបែងចែកទឹកដោយសមភាព និង ប្រសិទ្ធិភាព។
-ទទួលជំនួយពីក្រសួងធនធានទឹក និង ឧតុនិយម លើការងារគ្រប់គ្រងចាត់ចែង ការងារបច្ចេកទេស ការងាររាយការណ៍ ការងាររដ្ឋបាលកិច្ច និង ការងារវាយតំលៃ ។ល។
គោលនយោបាយនេះ នឹងត្រូវបានទទួលនូវការគាំទ្រពីច្បាប់គ្រប់គ្រងទឹកនាពេលអនាគត។

## ១_៣ និយមន័យ

### ១_៣_១ និយមន័យ នៃ ប្រព័ន្ធធារាសាស្ត្រគឺ:

-គំរោងធារាសាស្ត្រ គឺជាប្រភេទគំរោងដែលពាក់ព័ន្ធនឹងទឹកបំរើអោយការងារដាំដុះ សាងសង់ដោយរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដូចដែលបានបញ្ជាក់នៅក្នុងគោលនយោបាយនេះឬក៏គំរោងដែលបានបញ្ចប់ការសាងសង់ មុនពេលបង្កើតគោលនយោបាយនេះក៏ចាត់ទុកថាជារបស់រដ្ឋដែរ សំណង់ទាំងនេះស្ថិតនៅក្រោមកិច្ចដំណើរការរបស់ក្រសួងធនធានទឹក និង ឧតុនិយម។
-ប្រព័ន្ធធារាសាស្ត្រគឺជាសំណុំសំណង់ដែលពាក់ព័ន្ធនឹងការស្ទាក់ទឹក ស្តុកទឹក និង ចែកចាយទឹក រួមមានប្រភេទធំ មធ្យម និង តូច។ ពិនិត្យទៅលើលទ្ធភាពជាក់ស្តែង ប្រព័ន្ធទាំងនេះនឹងត្រូវបានប្រគល់ដល់សហគមន៍កសិករប្រើប្រាស់ទឹកធ្វើការគ្រប់គ្រង ជួសជុល ថែទាំ និង ដំណើរការ។ ចំពោះប្រព័ន្ធធារាសាស្ត្រដែលមានមុនគោលនយោបាយនេះ ក៏ត្រូវគិតដូចគ្នាដែរ។
-ប្រឡាយមេជាប្រឡាយដែលទទួលទឹកពីប្រភពទឹកដើម។
-ប្រឡាយរងទី១ជាប្រឡាយដែលទទួលទឹកពីប្រឡាយមេ។
-ប្រឡាយរងទី២ជាប្រឡាយដែលទទួលទឹកពីប្រឡាយរងទី១។
-ប្រឡាយរងទី៣ ឬ ជើងក្អែបជាប្រឡាយដែលនាំទឹកបញ្ចូលដល់ស្រែ។

**១_៣_២** ប្រព័ន្ធធារាសាស្ត្រដែលមានផ្ទៃដីស្រោចស្រពក្រោម ២០០ ហត ហៅថាខ្នាតតូច ពី ២០០ ហត ដល់ ៥០០០ ហត ហៅថាខ្នាតមធ្យម និង ធំជាង ៥០០០ ហត ឡើងទៅ ហៅថាខ្នាតធំ។

**១_៣_៣** សហគមន៍កសិករប្រើប្រាស់ទឹក គឺជាយន្តការមួយដែលបង្កើតឡើងដោយកសិករផ្ទាល់មានភារៈកិច្ចគ្រប់គ្រងប្រើប្រាស់ទឹកក្នុងប្រព័ន្ធធារាសាស្ត្រណាមួយដោយមានការទទួលស្គាល់ពីរាជរដ្ឋាភិបាល។ សហគមន៍កសិករប្រើប្រាស់ទឹកនេះ ដឹកនាំដោយគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក ដែលស្ថិតនៅក្រោមគណៈកម្មាធិការគាំទ្រសហគមន៍កសិករប្រើប្រាស់ទឹកជាអ្នកសំរបសំរួល។

១_៣_៤ ថ្លៃសេវាំនៃប្រព័ន្ធធារាសាស្រ្ត ជាថ្លៃដែលសហគមន៍កសិករប្រើប្រាស់ទឹក ប្រមូលបានពីការប្រើប្រាស់ទឹកក្នុងប្រព័ន្ធធារាសាស្ត្ររបស់ខ្លួន។

## ១_៤ គោលបំណង

១_៤_១ ដើម្បីទទួលបាននូវលទ្ធផលល្អ រក្សាបាននូវនិរន្តរភាព ម្ចាស់ការ និង បានសុវត្ថិភាពល្អក្នុងបរិស្ថាននៃប្រព័ន្ធធារាសាស្រ្ត។

១_៤_២ ដើម្បីជំរុញការងារធារាសាស្រ្តកសិកម្ម ធានាបាននូវសុវត្ថិភាពស្បៀងនិង បំរើអោយកិច្ចអភិវឌ្ឍន៍នៃសេដ្ឋកិច្ចជាតិ។

១_៤_៣ ដើម្បីបង្កើនជាបណ្តើរៗនូវតួនាទីនិង ភារៈកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹកនូវរាល់ដំណាក់កាលនៃកម្មវិធីអនុវត្ត ដោយកាត់បន្ថយបាននូវការទទួលខុសត្រូវរបស់រដ្ឋាភិបាលលើការងារអភិវឌ្ឍន៍វិស័យធារាសាស្រ្ត រួមមានការងារជួសជុល កិច្ចដំណើរការ និង លើការងារថែទាំ។

១_៤_៤ ដើម្បីកែលំអនូវសមត្ថភាពរបស់កសិករ និង សហគមន៍កសិករប្រើប្រាស់ទឹកក្នុងការគ្រប់គ្រង និង ការការពារប្រព័ន្ធធារាសាស្រ្ត។

១_៤_៥ ដើម្បីបង្កើនចំណេះដឹងអោយកសិករអំពីការទទួលខុសត្រូវលើការងារគ្រប់គ្រងប្រព័ន្ធធារាសាស្រ្ត និង ឈានអោយការផ្ទេរការងារគ្រប់គ្រងពីរដ្ឋទៅអោយសហគមន៍កសិករប្រើប្រាស់ទឹក។

១_៤_៦ ដើម្បីសំរួលអោយអ្នកផ្តល់ជំនួយជាតិ និង អន្តរជាតិក្នុងការបង្កើនថវិកាជំនួយលើការងារគ្រប់គ្រង និង អភិវឌ្ឍន៍វិស័យធារាសាស្រ្តកសិកម្មដែលពាក់ព័ន្ធយ៉ាងសកម្មជាមួយនិងកសិករប្រើប្រាស់ទឹក។

១_៤_៧ ដើម្បីនាំមកនូវការឯកភាព ក្នុងកិច្ចដំណើរការជ្រើសរើស និង ការអនុវត្តន៍ សំរាប់ការងារអភិវឌ្ឍន៍ ហើយនិងការងារគ្រប់គ្រងវិស័យធារាសាស្រ្ត រវាងស្ថាប័នរដ្ឋាភិបាលនានា និង ជំនួយឧបត្ថម្ភពីអង្គការជាតិ និង អន្តរជាតិ ដែលពាក់ព័ន្ធអោយការងារផ្សព្វផ្សាយលើវិស័យធារាសាស្រ្ត។

# ជំពូក២

## ២_១ ការផ្តល់គោលនយោបាយសំរាប់ការងារអភិវឌ្ឍន៏និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ

### ២_១_១

_កម្មវិធីផ្សព្វផ្សាយ ស្តារឡើងវិញ និង ការងារអភិវឌ្ឍន៏វិស័យធារាសាស្ត្រត្រូវតែអនុវត្តទៅតាមផែនការដែលបានរៀបចំរួច ហើយនិងទៅតាមតំរូវការរបស់ប្រជាកសិករភាគច្រើន។ ក្នុងកំឡុងពេលដែលធ្វើផែនការ និង អនុវត្តគំរោងធារាសាស្ត្រ ត្រូវមានការចូលរួមយ៉ាងពេញទំហឹងពីសំណាក់សហគមន៏កសិករប្រើប្រាស់ទឹក។ ការបង្កើតសហគមន៏កសិករប្រើប្រាស់ទឹកគឺជាការងារដំបូងបង្អស់ដើម្បីឈានទៅអនុវត្តន៏គំរោងសាងសង់ប្រព័ន្ធធារាសាស្ត្រមួយ។ បន្ទាប់ពីបានបញ្ចប់ការងារសាងសង់ប្រព័ន្ធធារាសាស្ត្ររួចមក ការងារទទួលខុសត្រូវលើកិច្ចដំណើរការនិង ការថែទាំ និង ការងារជួសជុលបន្ទាន់ផ្សេងៗ នឹងបញ្ជូនទៅអោយសហគមន៏កសិករប្រើប្រាស់ទឹក នៅក្នុងដំណាក់កាលជាជំហានៗដូចខាងក្រោមនេះ

+ក្នុងឆ្នាំទី១: រដ្ឋជួយចំណាយ ៨០% និង កសិករដែលជាសមាជិកសហគមន៏ជួយចំណាយ ២០%

+ក្នុងឆ្នាំទី២: រដ្ឋជួយចំណាយ ៦០% និង កសិករដែលជាសមាជិកសហគមន៏ជួយចំណាយ ៤០%

+ក្នុងឆ្នាំទី៣: រដ្ឋជួយចំណាយ ៤០% និង កសិករដែលជាសមាជិកសហគមន៏ជួយចំណាយ ៦០%

+ក្នុងឆ្នាំទី៤: រដ្ឋជួយចំណាយ ២០% និង កសិករដែលជាសមាជិកសហគមន៏ជួយចំណាយ ៨០%

+ក្នុងឆ្នាំទី៥: រដ្ឋជួយចំណាយ ០% និង កសិករដែលជាសមាជិកសហគមន៏ជួយចំណាយ ១០០%

ការចំណាយខាងលើនេះ អនុវត្តតែទៅលើប្រព័ន្ធធារាសាស្ត្រដែលបានសាងសង់រួចដោយថវិការរបស់រដ្ឋាភិបាល ឬក៏ជំនួយពីអង្គការជាតិ និង អន្តរជាតិ។

_សហគមន៏កសិករប្រើប្រាសទឹក នឹងត្រូវបានជំរុញដើម្បីអោយធ្វើផែនការ និងអភិវឌ្ឍន៏ប្រព័ន្ធស្រោចស្រពដោយប្រើប្រាស់នូវធនធានរបស់ខ្លួន។ អាស្រ័យលើសំណើររបស់សហគមន៏កសិករប្រើប្រាស់ទឹក រដ្ឋាភិបាលនឹងជួយឧបត្ថម្ភនូវជំនួយបច្ចេកទេស។

## ២_២ ផ្ទេរការទទួលខុសត្រូវលើការងារគ្រប់គ្រង និង ចែកចាយទឹក ទៅអោយសហគមន៏កសិករប្រើប្រាស់ទឹក

_ផ្អែកលើសមត្ថភាពនៃសហគមន៏កសិករប្រើប្រាស់ទឹក ប្រព័ន្ធស្រោចស្រពនឹងត្រូវបានផ្ទេរទៅអោយសហគមន៏កសិករប្រើប្រាស់ទឹក សំរាប់រក្សាការថែទាំ និង កិច្ចដំណើការដោយនិរន្តរភាព និង សំរាប់ជំរុញការងារធារាសាស្ត្រកសិកម្ម។ ប្រព័ន្ធធារាសាស្ត្រមិនមែនផ្ទេរទាំងស្រុងទៅអោយសហគមន៏កសិករប្រើប្រាស់ទឹកទេ តែវាជាការងារគ្រប់គ្រងរួមរវាងសហគមន៏កសិករប្រើប្រាស់ទឹក និង រដ្ឋាភិបាល។

_ជាការត្រឹមត្រូវនោះ គឺថាកិច្ចដំណើរការនៃការផ្ទេរប្រព័ន្ធស្រោចស្រព និង ការផ្ទេរហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ និង ការផ្ទេរការងារទទួលខុសត្រូវ គួរផ្តល់អោយសហគមន៏កសិករប្រើប្រាស់ទឹក ដែលមានការទទួលស្គាល់ពីរាជរដ្ឋាភិបាល។

បន្ទាប់ពីប្រព័ន្ធស្រោចស្រពត្រូវបានផ្ទេររួចមក ក្រសួងធនធានទឹក និង ឧតុនិយម (នាយកដ្ឋានធារាសាស្ត្រកសិកម្ម) ត្រូវតែរៀបចំនូវកិច្ចព្រមព្រៀងសំខាន់ៗជាមួយនិងសហគមន៍កសិករប្រើប្រាស់ទឹក សំរាប់ការប្រើប្រាស់អោយបានសមស្របនូវប្រព័ន្ធធារាសាស្ត្រ។

## ២_៣ ការងារបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក

**២_៣_១** ដូចដែលបានបញ្ជាក់ក្នុងចំណុច១_៣_៣នៃគោលនយោបាយនេះ រចនាសម្ព័ន្ធនៃសហគមន៍កសិករប្រើប្រាស់ទឹកគួរតែផ្អែកទៅតាមទំហំនៃប្រព័ន្ធធារាសាស្ត្រ។ លើសពីនេះទៅទៀតដើម្បីផ្តល់នូវការងារបច្ចេកទេសនិងឧបត្ថម្ភការគ្រប់គ្រងនៅក្នុងការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ក្រសួងធនធានទឹក និង ឧតុនិយម (នាយកដ្ឋានធារាសាស្ត្រកសិកម្ម) ត្រូវទទួលខុសត្រូវលើការងារចុះបញ្ជី ដើម្បីអោយ សកបទ ក្លាយជាយន្តការស្របច្បាប់។

**២_៣_២** សហគមន៍កសិករប្រើប្រាស់ទឹកនឹងត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកដែលជ្រើសរើសដោយសមាជិកសហគមន៍កសិករប្រើប្រាស់ទឹក។ គណៈកម្មាធិការមានការងារធ្វើដូចតទៅ:

- រៀបចំកម្មវិធីសំរាប់សហគមន៍
- តួនាទីការងារគឺអាស្រ័យទៅតាមលក្ខន្តិកៈរបស់សហគមន៍ដែលបានអនុម័តដោយសហគមន៍កសិករប្រើប្រាស់ទឹក និង ដោយមានការទទួលស្គាល់ពី ក្រសួងធនធានទឹក និង ឧតុនិយម។
- រៀបចំកិច្ចដំណើរការ និង ការងារថែទាំប្រព័ន្ធស្រោចស្រពដើម្បីប្រើប្រាស់ទឹកដោយសន្សំសំចៃ
- ដោះស្រាយវិបត្តិរបស់សមាជិកសហគមន៍
- ប្រមូលថ្លៃទឹកដែលបានកំណត់ដោយសហគមន៍កសិករប្រើប្រាស់ទឹក
- កំណត់ការទទួលខុសត្រូវនៃសហគមន៍កសិករប្រើប្រាស់ទឹកមួយទៅតាមទីតាំងនិងប្រភេទនៃគំរោងដែលបង្កើតដោយក្រសួងធនធានទឹក និង ឧតុនិយម។

**២_៣_៣** សហគមន៍កសិករប្រើប្រាស់ទឹក ត្រូវមានតំណាងកសិករមកពីគ្រប់ជាន់ថ្នាក់នៃប្រព័ន្ធស្រោចស្រព ដូចជាប្រឡាយរងជើងក្អែប ប្រឡាយរងទី២ ប្រឡាយរងទី១ និង ប្រឡាយមេ ឬក៏ ក្រុមកសិករប្រើប្រាស់ទឹក។ ការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក និង ការរៀបចំលក្ខន្តិកៈត្រូវតែជាការទទួលខុសត្រូវរបស់សហគមន៍កសិករប្រើប្រាស់ទឹក និង ក្រសួងធនធានទឹក និង ឧតុនិយម។

**២_៣_៤** ក្រុមកសិករប្រើប្រាស់ទឹកត្រូវមានភារកិច្ចដូចខាងក្រោមនេះ៖

- អនុវត្តន៍កម្មវិធីការងាររបស់សហគមន៍។
- សំរបសំរួលរវាងសមាជិករបស់សហគមន៍កសិករប្រើប្រាស់ទឹក និង សហគមន៍។

-ប្រមូលថ្លៃទឹកពីសមាជិកសហគមន៏កសិករប្រើប្រាស់ទឹកទៅតាមការកំណត់របស់សហគមន៏។

**២_៣_៥** កសិករណាដែលត្រូវការប្រើប្រាស់ទឹកសំរាប់ការដាំដុះត្រូវដាក់ពាក្យសុំចូលជាសមាជិកសហគមន៏និងសុខចិត្តបង់ថ្លៃទឹកដែលកំណត់ដោយ សហគមន៏កសិករប្រើប្រាស់ទឹក។

## ២_៤ ថ្លៃប្រើប្រាស់ទឹក

**២_៤_១** ការទទួលខុសត្រូវដើម្បីប្រមូលថ្លៃប្រើប្រាស់ទឹកពីកសិករអ្នកប្រើប្រាស់ទឹកសំរាប់សេវានៃប្រព័ន្ធស្រោចស្រព គឺគណៈកម្មាធិការសហគមន៏កសិករប្រើប្រាស់ទឹក ដែលបានចុះឈ្មោះជាមួយនិងរដ្ឋាភិបាលរួច។ ថ្លៃទឹក នឹងត្រូវបានសំរេចដោយសហគមន៏កសិករប្រើប្រាស់ទឹក ដែលណែនាំដូចខាងក្រោម:

$$Y = \frac{X1 + X2 + X3 + X4 + X5}{\text{ផ្ទៃដីស្រោចស្រព}} + 20\% \text{ នៃកំណើនទិន្នផលក្នុងមួយ ហត}$$

កំណត់សំគាល់:

- _X1=ជាចំណាយលើការថែទាំនិងជួសជុល
- -X2=ជាចំណាយលើប្រេងឥន្ទនៈបើសិនជាមានការបូម
- -X3=ជាចំណាយលើការចាយវាយរបស់សហគមន៏
- -X4=ជាចំណាយលើការងាររដ្ឋបាល
- -X5=ជាចំណាយលើការឥតប្រៀង
- _Y=ជាថ្លៃទឹកក្នុងមួយ ហត

តំលៃនៃការថែទាំ និង ជួសជុលអាចប្រែប្រួលពីប្រព័ន្ធមួយទៅប្រព័ន្ធមួយ ហើយនៅក្នុងប្រព័ន្ធតែមួយក្នុងឆ្នាំខុសគ្នាពេលនោះថ្លៃទឹកក៏ប្រែប្រួលដែរ និង ថ្លៃទឹកត្រូវកំណត់ដោយសហគមន៏កសិករប្រើប្រាស់ទឹក។ តំលៃ ២០% នៃកំណើនទិន្នផលត្រូវតែរក្សាទុកក្នុងបេឡានៃសហគមន៏កសិករប្រើប្រាស់ទឹក ចាត់ទុកថាជាថវិកាដើម្បីប្រើប្រាស់សំរាប់ចំណាយបន្ទាន់លើការងារថែទាំ និង ជួសជុល ឬក៏សហគមន៏កសិករប្រើប្រាស់ទឹកអាចចំណាយសំរាប់ធ្វើអោយកាន់តែទំនើបឡើងនូវប្រព័ន្ធស្រោចស្រពរបស់គេ ឬក៏កែលំអលើការងារកម្មវិធីគ្រប់គ្រងទឹកនៅនិងស្រែកសិករ។

ដើម្បីជាការងាយ ក្នុងសភាពការណ៏បច្ចុប្បន្ននេះ កំណើនទិន្នផលនៃស្រូវរដូវវស្សាដែលបានទទួលនូវការស្រោចស្រពប្រៀបធៀបនិងស្រូវវស្សាដែលពុំបានធ្វើការស្រោចស្រពគឺប្រមាណជា ០,៧ត ក្នុង១ ហត។ សហគមន៏កសិករប្រើប្រាស់ទឹកនឹងប្រមូលជារៀងរាល់ឆ្នាំ ១៤០គក្រ ក្នុង១ ហត នៃស្រូវ ដែលចាត់ទុកថាជាការចូលហ៊ុនគ្នានៃ២០%ក្នុងកំណើនទិន្នផល។

នេះត្រូវតែអនុវត្តជាបន្តបន្ទាប់សំរាប់៥ឆ្នាំដំបូង។ បន្ទាប់មកអាស្រ័យដោយស្ថានភាពថវិការបស់សហគមន៍ សហគមន៍កសិករប្រើប្រាស់ទឹកអាចបញ្ចុះតំលៃពី ២០%នៃកំណើនទិន្នផលទៅដល់តំលៃមួយតែមិនអោយតិចជាង៥%នៃកំណើនទិន្នផល។

២_៤_២ គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកមានភារៈកិច្ចប្រមូលថ្លៃទឹកនៅក្នុងប្រព័ន្ធធារាសាស្ត្ររបស់ខ្លួន រក្សាបញ្ជីរបស់កសិករ ដែលប្រើប្រាស់ទឹកដើម្បីធ្វើការស្រោចស្រពដំណាំ និង បញ្ជីផ្ទៃដីដាំដុះ ប្រភេទដំណាំ ។ល។

២_៤_៣ ថវិកាចំណូលនិង ចំណាយរបស់សហគមន៍កសិករប្រើប្រាស់ទឹកត្រូវតែមានការត្រួតពិនិត្យប្រចាំឆ្នាំដោយក្រុមអធិការកិច្ច។ របាយការណ៍ត្រូវតែរាយការណ៍ជូនសមាជិកសហគមន៍កសិករប្រើប្រាស់ទឹកតាមរយៈអង្គប្រជុំសាធារណៈមួយដើម្បីសុំការអនុម័ត។

## ២_៥ ទំនាក់ទំនង និង ការទទួលខុសត្រូវនៃស្ថាប័ននានា

២_៥_១ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហការក្នុងការរកលទ្ធភាពថវិការសំរាប់ ធ្វើការងារអភិវឌ្ឍន៍វិស័យធារាសាស្ត្រកសិកម្ម រួមមានការបង្កើតនិងការដំណើរការសហគមន៍កសិករប្រើប្រាស់ទឹករហូតដល់សហគមន៍អាចដំណើរការខ្លួនឯងបាន។ ការផ្តល់ថវិកាអោយបានគ្រប់គ្រាន់សំរាប់ធ្វើការថែទាំ និង ដំណើរការដូចដែលបានចែងក្នុងចំណុច ២_១ នៃគោលនយោបាយនេះ។

២_៥_២ ការងារទទួលខុសត្រូវដើម្បីផ្តល់ថវិកាកំចីសំរាប់ការងារកសិកម្មដូចជាតំរូវការវត្ថុធាតុដើម និងបច្ចេកទេសផលិតកម្មដែលត្រូវការដើម្បីធ្វើប្រពលវប្បកម្មលើការងារដាំដុះនៅក្នុងប្រព័ន្ធស្រោចស្រព ជាបន្ទុករបស់ ធនាគារកសិកម្ម និង ពាណិជ្ជកម្ម។ ធនាគារទាំងនេះត្រូវតែធ្វើសេវា និង រកលទ្ធភាពដើម្បីបំរើយ៉ាងសកម្មចំពោះសហគមន៍កសិករប្រើប្រាស់ទឹក។

២_៥_៣ ត្រូវបង្កើតនូវបរិយាកាសប្រមូលផ្តុំដើម្បីអោយអង្គការ ជាតិ អន្តរជាតិ និង អង្គការក្រៅរដ្ឋាភិបាលធ្វើការពាក់ព័ន្ធ និង ជំរុញការងារធារាសាស្ត្រកសិកម្ម តាមរយៈនៃការអភិវឌ្ឍន៍ដោយមាននិរន្តរភាព និង គ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ បែបនេះ នឹងមានការចូលរួមយ៉ាងសកម្មពីសំណាក់ស្ថាប័នសាធារណៈ និង ក្រុមហ៊ុនឯកជន។

២_៥_៤ ការងារទំនាក់ទំនងល្អជាមួយនិងអាជ្ញាធរ ខេត្ត ក្រុង ស្រុក ឃុំ ភូមិ និង សហគមន៍ដទៃៗទៀតដែលមានការពាក់ព័ន្ធ នឹងត្រូវបានកែលំអបន្ថែម។

## ២_៦ ការងារគ្រប់គ្រងទឹកសំរាប់ស្រោចស្រព និង ការងារបណ្តុះបណ្តាល

២_៦_១ ការងារគ្រប់គ្រងទឹកសំរាប់ស្រោចស្រពត្រូវអនុវត្តទៅតាមបច្ចេកវិទ្យានៃការស្រោចស្រព។ ផ្លូវតាមការងារនេះប្រព័ន្ធស្រោចស្រពនឹងត្រូវបានកែលំអជាប្រចាំដើម្បីអោយសមស្របទៅនឹងស្ថានភាពជាក់ស្តែង។

២_៦_២ ការងារអភិវឌ្ឍន៍ចំណេះដឹង និង ជំនាញ របស់សហគមន៍កសិករប្រើប្រាស់ទឹក និង មន្ត្រីបច្ចេកទេស ត្រូវតែអនុវត្តជាប្រចាំទៅតាមគំរូនៃវគ្គបណ្តុះបណ្តាលសមស្របមួយ។

## ២_៧ ការងារត្រួតពិនិត្យ និង វាយតំលៃ

២_៧_១ ប្រព័ន្ធធ្វើការត្រួតពិនិត្យ និងវាយតំលៃមួយត្រូវតែបានពង្រឹងដោយ ក្រសួងធនធានទឹក និង ឧតុនិយម ដោយរក្សា អោយមានលក្ខណៈថ្មីទំនើបទាន់សម័យនូវប្រព័ន្ធព័ត៌មានរបស់ក្រសួង ស្ថានភាពប្រព័ន្ធធារាសាស្ត្រ កសិកម្ម និង ការងារគ្រប់គ្រងនៃប្រព័ន្ធធារាសាស្ត្រនៅក្នុងប្រទេស។ សហគមន៍កសិករប្រើប្រាស់ទឹកត្រូវតែបានជំរុញ និង កែលំអសមត្ថភាព ដើម្បីជួយក្នុងកិច្ចការថែទាំប្រព័ន្ធទិន្នន័យមូលដ្ឋាននៅថ្នាក់ក្រោម។

២_៧_២ ក្នុងការងារវាយតំលៃលើប្រព័ន្ធធារាសាស្ត្រ ការងារកែលំអ និង ផ្សព្វផ្សាយក្នុងតំបន់សេវាស្រោចស្រព ការងារ ផ្លាស់ប្តូរ កាលវិភាគដាំដុះ ការងារប្រពលវប្បកម្ម និង ការងារកែលំអសមត្ថភាពសហគមន៍កសិករប្រើប្រាស់ទឹក លើការគ្រប់គ្រងជាមួយនិងការផ្តល់ផលប្រយោជន៍បន្ថែមខាងសេដ្ឋកិច្ច ជាបន្ទុករបស់ សកបទ។

២_៧_៣ នាយកដ្ឋានធារាសាស្ត្រកសិកម្ម ក្រសួងធនធានទឹក និង ឧតុនិយម ជាអង្គភាពដែលទទួលបន្ទុក ក្នុងការត្រួតពិនិត្យ និង វាយតំលៃលើការងាររបស់ប្រព័ន្ធធារាសាស្ត្រ និង កំណត់ការលំបាកនិងដំណោះស្រាយនិងចាត់ចែង អោយបានទាន់ពេលវេលានូវការធ្វើអន្តរាគមន៍។ សហគមន៍កសិករប្រើប្រាស់ទឹកត្រូវតែសហការដើម្បីធ្វើកិច្ចការនេះ។

# ជំពូក៣

## ៣_១ ការវាយតំលៃលើការងារបរិស្ថាន

៣_១_១ សំរាប់កិច្ចការដែលទើបតែចាប់ផ្តើម ចំពោះប្រព័ន្ធធារាសាស្ត្រដែលថ្មី ការវាយតំលៃលើផលប៉ះពាល់បរិស្ថាន ត្រូវតែអនុវត្ត ក្នុងពេលសិក្សាគំរោង។

៣_១_២ ការងារចែកចាយទឹកទៅអោយកសិករពីប្រព័ន្ធស្រោចស្រពមួយ ការងារដឹកនាំដើម្បីអោយមានការប្រើប្រាស់ទឹកបាន សមស្រប ត្រូវតែមានតម្លាភាពដើម្បីទទួលបាននូវផលិតភាពខ្ពស់ និងមាននិរន្តរភាព ទន្ទឹមនឹងនោះត្រូវតែពិចារណាយ៉ាងល្អិតល្អន់នូវវិធានការកាត់បន្ថយការបំពុលបរិស្ថាន។

៣_១_៣ ក្រសួងធនធានទឹក និង ឧតុនិយម នឹងពង្រឹងនូវកិច្ចសហប្រតិបត្តិការលើការងារការពារតំបន់ដីជំរាលជាមួយស្ថាប័ននិងអង្គភាពពាក់ព័ន្ធ។ កំណត់នៅក្នុងប្រភពទឹក ប្រព័ន្ធប្រឡាយ ការទប់ទន្លេ ទឹកជំនន់ និង ការចាក់ដីត្រូវតែពិនិត្យអោយបានយ៉ាងសកម្មតាមរយៈសំណើរបស់សហគមន៍កសិករប្រើប្រាស់ទឹក។

# ជំពូកទី៤

## ៤_១ ការងារអភិវឌ្ឍន៍ធនធានមនុស្ស និង ការងារស្រាវជ្រាវ

៤_១_១ ក្រសួងធនធានទឹក និង ឧតុនិយម នឹងធ្វើការកែលំអនូវកម្មវិធីបណ្តុះបណ្តាលនិងសំភារៈសំរាប់ការផ្ទេរនូវចំណេះដឹង និង ការងារអភិវឌ្ឍន៍ធនធានមនុស្ស។

៤_១_២ សំរាប់ការងារកែលំអជាបន្តនៅក្នុងប្រព័ន្ធធ្វើការងាររបស់មន្ត្រីរដ្ឋាភិបាលនិងទទួលបានលទ្ធផលល្អក្នុងកម្មវិធីស្រាវជ្រាវ និង បណ្តុះបណ្តាល ត្រូវតែបំរុញជារៀងរាល់ឆ្នាំនូវកម្មវិធីថ្នាក់ជាតិ ថ្នាក់ខេត្ត និង ថ្នាក់ស្រុក។

៤_១_៣ ជាចាំបាច់ណាស់ការងារអភិវឌ្ឍន៍ធនធានមនុស្ស គឺធ្វើការសិក្សាទៅលើការងារវាយតំលៃលើផលប៉ះពាល់បរិស្ថាន ការសិក្សាគ្រាងប្លង់ ការវិភាគលើការលំបាក ។ល។ ត្រូវតែរៀបចំដោយ នាយកដ្ឋានធារាសាស្រ្តកសិកម្ម។

## ៤_២ ផ្តល់ការកែលំអដល់គោលនយោបាយជាប្រចាំ

គោលនយោបាយនេះត្រូវតែពិនិត្យ និង កែសំរួលឡើងវិញរយៈពេល ៥ឆ្នាំម្តង បើសិនមានការចាំបាច់។ ក្រុមការងារមួយរបស់ក្រសួងធនធានទឹក និង ឧតុនិយម ត្រូវតែត្រួតពិនិត្យ និង ធ្វើការផ្លាស់ប្តូរដោយផ្អែកទៅលើបទពិសោធន៍ដែលមានកន្លងមក។

# ជំពូកទី៥

## ៥_១ ការងារផ្សេងៗ

៥_១_១ នាយកដ្ឋានធារាសាស្រ្តកសិកម្មនៃក្រសួងធនធានទឹក និង ឧតុនិយមត្រូវតែរៀបចំនូវបញ្ជីប្រព័ន្ធធារាសាស្រ្តដែលមានលទ្ធភាពអាចប្រើប្រាស់បាននៅតាមដងទន្លេ ស្ទឹង បឹងបួរ ដោយសហការជាមួយនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងធនធានទឹក និង ឧតុនិយម និង អង្គភាពដទៃទៀតក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍វិស័យធារាសាស្រ្ត

និងប្រើប្រាស់អស់លទ្ធភាពនូវសក្តានុពលធនធានទឹក និង ដី។ សក្តានុពលទឹកក្រោមដីសំរាប់ការងារស្រោចស្រពត្រូវតែធ្វើអាជីវកម្មនិងអភិវឌ្ឍន៏ដោយរក្សាការប្រើប្រាស់ធនធានទឹកអោយបានល្អត្រឹមត្រូវ និង ធានាបាននូវនិរន្តរភាព។

៥_១_២ តំរូវការធនធានមនុស្ស និង របនាសម្ព័ន្ធរបស់នាយកដ្ឋានធារាសាស្ត្រកសិកម្មគួរតែសំរួល និង ពង្រីកបើសិនជាចាំបាច់។

# ផ្នែកទី ៣

## ជំហាន

## នៃ

## ការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ជំហាននៃការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក

រៀបរៀង អោយក្រសួងធនធានទឹក និង ឧតុនិយម

ខែ មិនា ឆ្នាំ ២០០០

# ជំហាននៃការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក

## សេចក្តីផ្តើម

គោលនយោបាយសំរាប់ កិច្ចដំណើរការ និង ថែទាំប្រព័ន្ធធារាសាស្ត្រដោយនិរន្តរភាព របស់ក្រសួងធនធានទឹក និង ឧតុនិយម បានទទួលស្គាល់អំពីតួនាទីនៃសហគមន៍កសិករប្រើប្រាស់ទឹកនៅក្នុងការគ្រប់គ្រង និង អភិវឌ្ឍន៍វិស័យធារាសាស្ត្រ។ សហគមន៍កសិករប្រើប្រាស់ទឹកគឺមានតួនាទីសំខាន់ណាស់ក្នុងការផ្តល់សេវាទឹក តាមតំរូវការ ទាន់ពេលវេលា និង មានតម្លាភាព ដល់កសិករ ដើម្បីកែលំអនូវការអនុវត្តនៃប្រព័ន្ធធារាសាស្ត្រមួយ ក៏ដូចជាកិច្ចដំណើរការ និង គ្រប់គ្រងប្រព័ន្ធធារាសាស្ត្រអោយមាននិរន្តរភាព។ អ្វីដែលយើងគ្រោងទុកនោះគឺថាសហគមន៍កសិករប្រើប្រាស់ទឹកជាយន្តការ ស្របច្បាប់មួយ បានការអនុញ្ញាតិពីរដ្ឋាភិបាល ដើម្បីប្រមូលថ្លៃប្រើប្រាស់ទឹកសំរាប់ផ្គត់ផ្គង់សេវាទឹក និង សំរាប់កិច្ចដំណើរការ និង ការថែទាំប្រចាំឆ្នាំ និង ត្រៀមសំរាប់តំរូវការបន្ទាន់លើការងារថែទាំសំណង់ធារាសាស្ត្រ។

គោលនយោបាយនេះ មានបំណងផ្ទេរការទទួលខុសត្រូវលើការងារគ្រប់គ្រងទៅអោយសហគមន៍កសិករប្រើប្រាស់ទឹក។ ករណីនេះអនុវត្តសំរាប់ទៅលើប្រព័ន្ធធារាសាស្ត្រណាដែលគ្រប់គ្រងដោយរដ្ឋាភិបាល។ សហគមន៍កសិករប្រើប្រាស់ទឹក ជាយន្តការមួយដែលមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន។ ពួកគេត្រូវបានទទួលតំលៃសេវាដែលសមាជិកសហគមន៍ផ្តល់អោយ។ ពួកគេត្រូវតែគ្រប់គ្រង និង ឧបត្ថម្ភថវិកាដោយកសិករប្រើប្រាស់ទឹក។ ពួកគេត្រូវតែមានការកែលំអមួយលើកម្មវិធីរក្សាទុកបញ្ជីគណនេយ្យ និង បញ្ជីចែកចាយទឹក ការកែលំអនូវកំលាំងការងារគ្រប់គ្រងទឹក និង ត្រួតពិនិត្យការបោះឆ្នោតជ្រើសរើសគណៈកម្មាធិការសហគមន៍តាមរយៈការបោះឆ្នោតសំងាត់។

សហគមន៍កសិករប្រើប្រាស់ទឹកមួយ ដើម្បីរៀបចំតំរូវការថវិកា និងតំរូវការសំរាប់ដំណើរការនិងថែទាំប្រព័ន្ធធារាសាស្ត្រ ដើម្បីកែលំអសេវាម្ចាស់ការលើទឹក និង សេវារក្សាទឹក ទាមទារអោយមានកំលាំងការងារគ្រប់គ្រងទឹក ការិយាល័យតូចមួយសំរាប់ធ្វើការងារ រោងជាងតូចមួយសំរាប់ធ្វើការងារជួសជុល និង ត្រូវជួសជុលរាល់សំភារៈឧបករណ៍សំរាប់ថែទាំប្រព័ន្ធធារាសាស្ត្រ។ សហគមន៍ ក៏ត្រូវមានផងដែរនូវការកែទំរង់ថវិកា វិក័យប័ត្រត្រូវរក្សាទុក រៀបចំអង្គប្រជុំសំរាប់សហគមន៍ របាយការណ៍ចំណូលចំណាយ តភានូវការទទួលខុសត្រូវផ្សេងៗ ការងារបិទបើកចែកចាយទឹក ការងារជួសជុលបន្ទាន់ផ្សេងៗ ការងាររៀបចំការបោះឆ្នោត និង ការងារប្រចាំថ្ងៃផ្សេងៗទៀត។ តើការងារអ្វីផ្សេងទៀតដែលសហគមន៍កសិករប្រើប្រាស់ទឹកត្រូវធ្វើ ថាតើពួកគេគួរចង់ធ្វើសហគមន៍មានគោលបំណងតែមួយឬក៏ពហុគោលបំណង ការងារនេះគួរទុកជូនសហគមន៍កសិករប្រើប្រាស់ទឹកជាអ្នកសំរេច។

ប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះគឺមានការកើនឡើងនូវការយល់ដឹង និង ការទទួលយក នូវការចូលរួមពីអ្នកប្រើប្រាស់ទឹកគ្រប់ថ្នាក់ក្នុងការងារអភិវឌ្ឍន៍ និង គ្រប់គ្រង ប្រព័ន្ធធារាសាស្ត្រ ដែលជាហេតុធ្វើអោយមានការកែលំអ និង រក្សានិរន្តរភាពរបស់ប្រព័ន្ធស្រោចស្រពអោយបានយូរអង្វែង។ រីឯការជំរុញការងារសាងសង់ និងការងារកែលំអប្រព័ន្ធធារាសាស្ត្រ មិនទាន់អាច

ធ្វើអោយមានការផ្លាស់ប្តូរលើវិស័យធារាសាស្ត្រឡើយ។ ជាការពិតកសិករនឹងត្រូវការនូវការកែលំអរហេដ្ឋារចនាសម្ព័ន្ធដើម្បីចាប់យកនូវតំរូវការប្រព័ន្ធធារាសាស្ត្រទំនើប និង តំរូវការរបស់ទីផ្សារ។ ទោះបីជាយ៉ាងណាក៏ដោយចុះកម្មវិធីបណ្តុះបណ្តាលសំរាប់មន្ត្រីបច្ចេកទេស និង កសិករ ក៏នឹងត្រូវតែចាប់ផ្តើម។ ការងារអភិវឌ្ឍន៏សហគមន៏កសិករប្រើប្រាស់ទឹកនឹងមានទិសដៅទៅជាយន្តការមួយដែលប្រើប្រាស់ប្រព័ន្ធស្រោចស្រពរួមគ្នា មានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងទឹក រក្សានិរន្តរភាពដោយខ្លួនឯងនូវការងារហិរញ្ញកិច្ច និង មានកម្មវិធីចែកចាយទឹកដោយមានប្រសិទ្ធភាព។

ភាពក្រីក្រ អនក្ខរកម្ម បញ្ហាជនជាតិភាគតិចរស់ក្នុងមូលដ្ឋាន និង វិសមភាពសេដ្ឋកិច្ចរបស់ប្រជាជននៅមូលដ្ឋាន មិនមែនកំណត់ថាជាកត្តាអសកម្មនៅក្នុងការអភិវឌ្ឍន៏សហគមន៏កសិករប្រើប្រាស់ទឹកឡើយ។ តំរូវការជំនាញ និង ចំណេះដឹង ដើម្បីរៀបចំ និង ដំណើរការសហគមន៏កសិករប្រើប្រាស់ទឹកគួរតែផ្តល់តាមរយៈសិក្ខាសាលា និង វគ្គបណ្តុះបណ្តាលសំរាប់កសិករ។

## ដំណើការបង្កើតសហគមន៏

ជំនួយក្នុងការកែលំអប្រព័ន្ធស្រោចស្រពមួយដោយរាជរដ្ឋាភិបាល ឬក៏ដោយស្ថាប័នអ្នកផ្តល់ជំនួយ ឬក៏ដោយអង្គការក្នុង និង ក្រៅរដ្ឋាភិបាល ត្រូវតែអនុវត្តន៏តាមគោលនយោបាយសំរាប់ កិច្ចដំណើរការ និង ថែទាំប្រព័ន្ធធារាសាស្ត្រ ដោយមាននិរន្តភាព។ ដំណើរការរៀបចំនេះបានត្រូវពិចារណា ដើម្បីចាប់ផ្តើមធ្វើការរៀបចំសហគមន៏កសិករប្រើប្រាស់ទឹកដែលនៅក្នុងនោះ កសិករគឺត្រូវបានរៀបចំទៅតាមក្រុមខុសៗគ្នា ដែលអាស្រ័យទៅតាមទំហំនៃប្រព័ន្ធធារាសាស្ត្រ។ កិច្ចដំណើរការ សកបទ ត្រូវអនុវត្តទៅតាមគំនូសរូបខាងក្រោម:



ដំណើរការផ្សេងៗនៃការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកបានត្រូវចែកចេញជាបណ្ដាជំហានដូចខាងក្រោម។ បណ្ដាជំហានទាំងនេះបង្ហាញនូវការងារផ្សេងៗដែលត្រូវសំរេចអោយខាងតែបានដើម្បីអភិវឌ្ឍន៍នូវការគ្រប់គ្រងរចនាសម្ព័ន្ធនៃសហគមន៍កសិករប្រើប្រាស់ទឹក។

**<u>ជំហានទី១:</u>** ដំណើរការនៃការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកគួរតែអនុវត្តន៍តាមនិតិវិធីចំហ និង សាធារណៈ។ ការប្រជុំជាច្រើននៃសហគមន៍ត្រូវបានប្រារព្ធឡើងដើម្បីអនុវត្តន៍នូវកម្មវិធីការងាររបស់សហគមន៍កសិករប្រើប្រាស់ទឹក។ នៅក្នុងបណ្ដាការប្រជុំទាំងនេះ កសិករទាំងអស់នៃប្រព័ន្ធស្រោចស្រព ត្រូវបានផ្ដល់ពត៌មានស្ដីអំពីគោលបំណងនៃ កម្មវិធី ក៏ដូចជាការងារបន្តបន្ទាប់ដែលត្រូវអនុវត្តន៍នៅពេលអនាគត។ គោលបំណងនៃការប្រជុំត្រូវបានជូនដំណឹងទៅអោយកសិករប្រើប្រាស់ទឹកទាំងអស់ដោយលំអិតស្ដីពីការងារពេលអនាគត និង បញ្ជាក់អោយបានច្បាស់លាស់ថាប្រព័ន្ធស្រោចស្រព នឹងត្រូវបានគ្រប់គ្រងដោយកសិករ ការស្ម័គ្រចិត្តរបស់កសិករចូលជាសហគមន៍ នឹងត្រូវបានរកឃើញក្នុងបណ្ដាអង្គប្រជុំទាំងនោះ។ ចំនួនអង្គប្រជុំនឹងត្រូវបានបង្កើតឡើង អាស្រ័យនិងទំហំរបស់ប្រព័ន្ធស្រោចស្រព។

**<u>ជំហានទី២:</u>** ការបង្កើតនូវក៏រិត

គឺជាការចំបាច់ណាស់ ត្រូវតែយល់អោយបានច្បាស់នូវសណ្ឋានភាពនៃទឹក របស់ប្រព័ន្ធស្រោចស្រពទាំងអស់ដើម្បីជួយកសិករក្នុងការបង្កើតនូវសហគមន៍កសិករប្រើប្រាស់ទឹកមួយដ៏រឹងមាំ។

ក្នុងប្រព័ន្ធស្រោចស្រពភាគច្រើននឹងត្រូវការអោយមានគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកដែលសំរាប់ទទួលខុសត្រូវលើ ការគ្រប់គ្រងប្រឡាយមេ និង ឈានទៅធ្វើការគ្រប់គ្រងអាងទឹក ឬក៏ ប្រភពទឹកនាថ្ងៃអនាគត។ តែបើប្រព័ន្ធស្រោចស្រពនោះវាចំប្រកបដោយលក្ខណៈខុសៗគ្នាទៅតាមក៏រិតមាន ប្រឡាយមេ ប្រឡាយរងទី១ ប្រឡាយរងទី២ និង ប្រឡាយរងជើងក្អែបនេះ នឹងត្រូវការជាទូទៅដើម្បីបំបែកអោយទៅជាក្រុមប្រើប្រាស់ទឹកតូចៗនៅថ្នាក់ក្រោម។ ទោះជាយ៉ាងណាក៏ដោយការដាក់ទៅជាក្រុមតូចៗនឹងភ្ជាប់គ្នាជាមួយគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក និង គណៈកម្មាធិការទ្រទ្រង់នៃសហគមន៍កសិករប្រើប្រាស់ទឹកក្នុងប្រព័ន្ធធារាសាស្ត្រមួយ។

**<u>ជំហានទី៣:</u>** ការបង្កើតគណៈកម្មាធិការទ្រទ្រង់សហគមន៍កសិករប្រើប្រាស់ទឹក

វាជាលក្ខណៈប្រជាធិបតេយ្យណាស់នៃដំណើរការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក ខស្សេនៈនៃការធ្វើប្រជាមតិបោះឆ្នោតដោយសមាជិករបស់គណៈកម្មាធិការទ្រទ្រង់សហគមន៍កសិករប្រើប្រាស់ទឹកមួយ ដែលជាតំណាងអោយប្រជាកសិករទាំងអស់ដែលនៅជុំវិញប្រព័ន្ធស្រោចស្រពមួយជាធម្មតាត្រូវធ្វើ។ ក្នុងករណីដែលប្រព័ន្ធស្រោចស្រពមួយវាតូចពេក គណៈកម្មាធិការទ្រទ្រង់សហគមន៍កសិករប្រើប្រាស់ទឹកអាចទទួលយកកសិករប្រើប្រាស់ទឹកទាំងអស់ជាសមាជិក។ ចំពោះប្រព័ន្ធធារាសាស្ត្រខ្នាតធំ វាគួរតែប្រើនិតិវិធីចាត់តំណាងដែលតំណាងនោះជួសមុខអោយបណ្ដាកសិករដែលមានផ្ទៃដី៥០ហេកតា ហើយតំណាងនេះត្រូវបានជ្រើសរើសដោយសមាជិករបស់ខ្លួនអោយទៅឈរនៅគណៈកម្មាធិការទ្រទ្រង់សហគមន៍កសិករប្រើប្រាស់ទឹក។ តំណាងគណៈកម្មាធិការមកពីប្រឡាយរងទី២ និង ប្រឡាយរង១ នៅក្នុងគណៈកម្មាធិការទ្រទ្រង់សហគមន៍កសិករប្រើប្រាស់ទឹក គួរតែពិចារណា។

កិច្ចការដ៏សំខាន់របស់គណៈកម្មាធិការគ្រប់គ្រងសហគមន៍កសិករប្រើប្រាស់ទឹកគឺការកំណត់នូវការថែទាំ ត្រួតពិនិត្យ និង គុណភាពនៅក្នុងសកម្មភាពការងាររបស់សហគមន៍កសិករប្រើប្រាស់ទឹក។ ការងារកំណត់ថ្លៃទឹក ការងារកែតំរូវ និង អនុម័តលើរចនាសម្ព័ន្ធរបស់សហគមន៍កសិករប្រើប្រាស់ទឹក ការងារបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក ពិនិត្យ និង អនុម័តថវិកា និង ចំណាយផ្សេងៗ គឺជាបន្ទុកការងារខ្លះៗរបស់សហគមន៍កសិករប្រើប្រាស់ទឹក។

**ជំហានទី៤:** ការងារជ្រើសរើសអ្នករៀបចំកសិករ

អាស្រ័យលើទីតាំង និង ស្ថានភាពភូមិសាស្ត្រ ប្រព័ន្ធធារាសាស្ត្រទាំងមូលអាចចែកចេញជាតំបន់ ឬ ប្លុក។ តំបន់ធ្វើការងារនីមួយៗត្រូវចងក្រងអ្នករៀបចំកសិករអោយឆាប់បំផុត។ តំបន់នីមួយៗត្រូវកំណត់ពេលវេលា និង ទីកន្លែងដើម្បីជ្រើសរើសអ្នករៀបចំកសិករក្នុងប្រព័ន្ធធារាសាស្ត្រតែមួយ។ អ្នករៀបចំកសិករមានតួនាទីចាត់ចែងរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក និង ប្រមូលបញ្ជីកសិករនៅក្នុងប្រព័ន្ធធារាសាស្ត្រទាំងមូល។ នៅក្នុងកិច្ចដំណើរការជ្រើសរើសអ្នករៀបចំកសិករ បណ្តាកសិករ គួរតែជំរុញនូវការជ្រើសរើសមនុស្សពីក្រុមរបស់ខ្លួនដែលអ្នកទាំងនោះអាចអាន សរសេរ មានសមត្ថភាពយល់ និង ជាមនុស្សគួរអោយទុកចិត្តបាន ហើយមានដីដែលស្ថិតនៅក្នុងប្រព័ន្ធធារាសាស្ត្រ។ កសិករទាំងអស់នៃតំបន់នីមួយៗត្រូវជ្រើសរើសអ្នករៀបចំកសិករមួយក្រុមទៅតាមការពិភាក្សាគ្នាទៅវិញទៅមក។ ក្រុមនៃអ្នករៀបចំកសិករដែលបានជ្រើសរើសរួចនឹងត្រូវទទួលបាននូវវគ្គបណ្តុះបណ្តាលដែលទាក់ទងនឹងតួនាទីរបស់គេ និង ដំណើរការនៃការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ។ល។

**ជំហានទី៥:** ការពិភាក្សាលើសេចក្តីព្រាងលក្ខន្តិកៈសហគមន៍កសិករប្រើប្រាស់ទឹក

នេះជាការណែនាំដើម្បីបង្កើតនូវគណៈកម្មការមួយសំរាប់ធ្វើសេចក្តីព្រាងលក្ខន្តិកៈសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីបង្កើតលក្ខន្តិកៈ សំរាប់សហគមន៍ ដើម្បីសុំចុះបញ្ជីរបស់គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកជាមួយរដ្ឋាភិបាល។ គណៈកម្មការព្រាងលក្ខន្តិកៈ គួរបង្កើតឡើងដោយកំណត់ទៅតាមតំបន់នីមួយៗក្នុងជំហានទីបួន។ សមាសភាពសំរាប់ត្រៀមចូលជាគណៈកម្មការការងារព្រាងលក្ខន្តិកៈសហគមន៍កសិករប្រើប្រាស់ទឹក គឺត្រូវតែខុសពីសមាសភាព អ្នករៀបចំកសិករ។

គណៈកម្មការព្រាងនេះនឹងមានលទ្ធភាពធ្វើការពិភាក្សាផ្តល់យោបល់ និង ធ្វើការកែសំរួល លើសេចក្តីព្រាងលក្ខន្តិកៈដែលរៀបចំដោយរដ្ឋាភិបាល រួចដាក់ជូនគណៈកម្មាធិការគ្រប់គ្រងសហគមន៍កសិករប្រើប្រាស់ទឹក ឬក៏ការប្រជុំសហគមន៍កសិករប្រើប្រាស់ទឹកដើម្បីអនុម័ត។ សេចក្តីព្រាងលក្ខន្តិកៈនេះ គួតែពិភាក្សាគ្នាអោយបានល្អិតល្អន់ក្នុងអង្គប្រជុំគណៈកម្មាធិការគ្រប់គ្រងសហគមន៍កសិករប្រើប្រាស់ទឹក។

**ជំហានទី៦:** ការងារបង្កើតគណៈកម្មការសហគមន៍កសិករប្រើប្រាស់ទឹកនៅក្នុងប្រព័ន្ធធារាសាស្ត្រទាំងមូល

ដំណើរការនៃការបង្កើតគឺត្រូវបានចាប់ផ្តើមដោយផ្អែកលើព្រំដែននៃប្រព័ន្ធទឹកដែលចាប់ផ្តើមឡើងពីប្រឡាយរងជើងក្អែប ប្រឡាយរងទី២ រហូតដល់ប្រព័ន្ធប្រឡាយមេ។ ការងារបង្កើតគណៈកម្មាធិការកំពូល (សហគមន៍កសិករប្រើប្រាស់ទឹក) ជាដំបូង មិនគួរអនុវត្តន៍ និង បង្កើតពីប្រឡាយមេមកទេ គឺគួរចាប់ផ្តើមពីប្រឡាយរងដែលតូចជាងគេ ធ្វើបែប

នេះគឺដើម្បីផ្តល់នូវ ចំណេះដឹងគ្រប់គ្រាន់ដល់អ្នកប្រើប្រាស់ទឹកទាំងអស់នៅក្នុងប្រព័ន្ធ ហើយផ្តល់នូវការត្រួតពិនិត្យ និង គុណភាពនៅក្នុងរចនាសម្ព័ន្ធសហគមន៍កសិករប្រើប្រាស់ទឹក។

**ជំហានទី៧:** ការអនុម័តជាចុងក្រោយនៃលក្ខន្តិកៈសំរាប់សហគមន៍កសិករប្រើប្រាស់ទឹក

បន្ទាប់ពីការរៀបចំហើយជាស្រេចនូវគណៈកម្មាធិការត្រួតពិនិត្យ និងគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក គណៈកម្មាធិការទាំងពីរនេះរួមជាមួយការជួយឧបត្ថម្ភពីអ្នករៀបចំកសិករ និង មន្ត្រីបច្ចេកទេសរបស់ក្រសួងធនធានទឹក និង ឧតុនិយម អាចបង្កើត បាននូវសេចក្តីព្រាងបញ្ចប់ និង អនុម័តលក្ខន្តិកៈសំរាប់សហគមន៍កសិករប្រើប្រាស់ទឹក។ វាជាការសំខាន់ណាស់ដែលអោយគណៈកម្មាធិការត្រួតពិនិត្យសហគមន៍កសិករប្រើប្រាស់ទឹកធ្វើការពាក់ព័ន្ធជាមួយការអនុម័តលក្ខន្តិកៈ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មការធ្វើសេចក្តីព្រាង និង គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកមានតួនាទីសំខាន់នៅក្នុងដំណើរការព្រាងឬកែតំរូវលក្ខន្តិកៈ។ គណៈកម្មាធិការត្រួតពិនិត្យសហគមន៍កសិករប្រើប្រាស់ទឹកនឹងផ្តល់នូវ ការត្រួតពិនិត្យ និង គុណភាព ចំពោះដំណើរការនេះ ហើយសំខាន់ជាងនេះទៅទៀតគឺអោយ សភាបទ យល់ពីតួនាទីរបស់ខ្លួន។

**ជំហានទី៨:** ការចុះបញ្ជីនៃលក្ខន្តិកៈ និង គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក

ជាមួយនិងបណ្តាជំហានខាងលើការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹកនៅកំរិតផ្សេងៗនៃប្រព័ន្ធធារាសាស្ត្រគឺត្រូវបានបញ្ចប់ជាមួយនិងលក្ខន្តិកៈ។ គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកក៏ត្រូវធ្វើការពាក់ព័ន្ធផងដែរជាមួយនិងស្ថាប័នពាក់ព័ន្ធមួយចំនួន ដើម្បីបំពេញសំណុំបែបបទពាក់ព័ន្ធអោយសហគមន៍របស់ខ្លួនក្លាយជាសហគមន៍កសិករប្រើប្រាស់ទឹកគ្រប់លក្ខណៈ។ គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកត្រូវតែឆ្លងការធានាពីនាយកដ្ឋានធារាសាស្ត្រកសិកម្ម និង ការយល់ព្រមពីក្រសួងធនធានទឹក និង ឧតុនិយម ដើម្បីធ្វើការចុះបញ្ជីជាមួយក្រសួងធនធានទឹក និង ឧតុនិយម។

អង្គភាពពាក់ព័ន្ធក្រោមឱវាទស្ថាប័នក្រសួងធនធានទឹក និង ឧតុនិយមក្រោយពីពិនិត្យលក្ខន្តិកៈនិងដំណើរការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ត្រូវតែចេញ នូវការរៀបចំលិខិតបទដ្ឋានសំរាប់ចុះឈ្មោះជូនគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក។